អង្គការសហប្រជាជាតិ

A/HRC/៣៩/៧៣

# មហាសន្និបាត

ចែកចាយ៖ ទូទៅ
ថ្ងៃទី១៥ សីហា ២០១៨
អត្ថបទដើម៖ ភាសាអង់គ្លេស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស
សម័យប្រជុំលើកទីសាមសិបប្រាំបួន
ថ្ងៃទី១០ - ២៨ ខែកញ្ញា ឆ្នាំ២០១៨
របៀបវារៈ ចំណុចទី ១០
**ជំនួយផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

## របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា

### កំណត់សង្ខេបដោយលេខាធិការដ្ឋាន

លេខាធិការដ្ឋានមានកិត្តិយសសូមរៀបចំបញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនូវរបាយការណ៍របស់អ្នកស្រី រ៉ូណា ស្ម៊ីត ដែលជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ហើយដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងដោយអនុលោមតាមសេចក្តីសម្រេចចិត្តលេខ ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ របាយការណ៍នេះគ្របដណ្តប់លើរយៈពេលចាប់ពី ខែ មិថុនា ឆ្នាំ ២០១៧ រហូតដល់ ខែ មិថុនា ឆ្នាំ ២០១៨ ដែលនៅក្នុងអំឡុងពេលនោះអ្នករាយការណ៍ពិសេសបានបំពេញបេសកកម្មចំនួនពីរលើកទៅកាន់ប្រទេសកម្ពុជា។

អ្នករាយការណ៍ពិសេសសង្កេតឃើញថាកំណើនសេដ្ឋកិច្ចដ៏រឹងមាំបានផ្តល់ធនធានដើម្បីលើកកម្ពស់ដល់កិច្ចគាំការពារសង្គម និងលទ្ធភាពទទួលបានការអប់រំ ការងារសមរម្យ និងតំហែទាំសុខភាព។ ទោះបីជាយ៉ាងណាក៏ដោយ លោកស្រីសម្តែងក្តីបារម្ភអំពីដំណើរថយក្រោយនៃសិទ្ធិនយោបាយ និងការប្រើប្រាស់សេរីភាពជាមូលដ្ឋានដែលបន្តមានផលប៉ះពាល់ដល់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សទាំងអស់នៅក្នុងប្រទេស។ ដោយឡែកអ្នកការពារសិទ្ធិមនុស្សត្រូវប្រឈមនឹងហានិភ័យគួរឲ្យកត់សម្គាល់។

## I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានរៀបចំបញ្ជូនដោយអនុលោមតាមសេចក្តីសម្រេចចិត្តលេខ ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅក្នុងអំឡុងឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យនេះ អ្នករាយការណ៍ពិសេសបានឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា បានទទួលព័ត៌មានពីភាគីពាក់ព័ន្ធនានា រួមមាន រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋដែលជាបុគ្គលឯកជន។ អ្នករាយការណ៍ពិសេសបានបំពេញបេសកកម្មចំនួនពីរលើកទៅកាន់ប្រទេសកម្ពុជា៖ ចាប់ពីថ្ងៃទី៨ ដល់ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ហើយនិងចាប់ពីថ្ងៃទី៥ ដល់ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។ របាយការណ៍នេះ គ្រប់ដណ្តប់លើរយៈពេលចាប់គិតចាប់ពីខែមិថុនា ឆ្នាំ ២០១៧ ដល់ ខែមិថុនា ឆ្នាំ២០១៨ ដោយឆ្លុះបញ្ចាំងតាមរយៈរបកគំហើញផ្សេងៗបន្ទាប់ពីការបំពេញបេសកកម្មទាំងពីរលើក ព្រមទាំងព័ត៌មានដទៃទៀតដែលទទួលបាននៅក្នុងរយៈពេលមួយឆ្នាំពេញ។

២. អ្នករាយការណ៍ពិសេសសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលចំពោះការផ្តល់កិច្ចសហប្រតិបត្តិការនៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់លោកស្រី។

៣. ក្នុងកំឡុងពេលបពេញបេសកកម្មនេះ អ្នករាយការណ៍ពិសេសបានជួបប្រជុំជាមួយតំណាងរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងដៃគូអភិវឌ្ឍន៍ដទៃផ្សេងទៀត។ ជាពិសេស អ្នករាយការណ៍ពិសេសបានជួបប្រជុំជាមួយសម្តេច ហេង សំរិន ប្រធានរដ្ឋសភា, សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ឯកឧត្តម កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា, ឯកឧត្តម ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍, ឯកឧត្តម យូរ ឧត្តរា អនុប្រធានតុលាការកំពូល, ឯកឧត្តម ស៊ូ អារ៉ាហ្វាត អភិបាលរងខេត្តបាត់ដំបង, ហើយនិង ឯកឧត្តម អ៊ុំ រាត្រី អភិបាលរងខេត្តបន្ទាយមានជ័យ។ លោកស្រីក៏បានជួបប្រជុំជាមួយ ឯកឧត្តម កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិដែលបច្ចុប្បន្នត្រូវបានរំលាយ ក្នុងខែសីហា ឆ្នាំ២០១៧ ព្រមទាំងតួអង្គនយោបាយ និងអ្នកពាក់ព័ន្ធដទៃផ្សេងទៀត។

៤. រឿងដែលគួរឲ្យសោកស្តាយគឺថានៅក្នុងអំឡុងពេលនៃបេសកកម្មទាំងពីរលើកនោះ លោកស្រីត្រូវបានបដិសេធមិនឲ្យធ្វើការជួបសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ហើយជាក់ស្តែងគឺត្រូវបានបដិសេធមិនឲ្យទៅជួបលោក កឹម សុខា នៅឯមណ្ឌលអប់រំកែប្រែទី ៣។ អ្នករាយការណ៍ពិសេសបានធ្វើទស្សនកិច្ចទៅមជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្អ) មណ្ឌលអប់រំកែប្រែទី១ និង ទី២ និងពន្ធនាគាររាជធានីភ្នំពេញ។ ក្នុងអំឡុងពេលធ្វើទស្សនកិច្ចនៅខេត្តបាត់ដំបង និងនៅខេត្តបន្ទាយមានជ័យ ក្នុងខែសីហា ឆ្នាំ២០១៧ លោកស្រីត្រូវបានអញ្ជើញឲ្យទៅទស្សនាមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងមជ្ឈមណ្ឌលស្តារនីតិ-សម្បទាអ្នកញៀនគ្រឿងញៀនជីវិតថ្មី។

៥. នៅទីបញ្ចប់ អ្នករាយការណ៍ពិសេសត្រូវបានលើកទឹកចិត្តតាមរយៈការបង្ហាញឆន្ទៈរបស់រដ្ឋាភិបាលឆ្លើយតបទៅនឹងលិខិតប្តឹងបន្ទាន់ឬលិខិតស្នើសុំបកស្រាយលើករណីចោទប្រកាន់ ដែលធ្វើដោយអ្នកជំនាញកាន់អាណត្តិ

នីតិវិធីពិសេស ហើយសម្តែងស្វាគមន៍ឱកាសសម្រាប់ការសន្ទនា និងការយល់ដឹងកាន់តែស៊ីជម្រៅថែមទៀតនាពេលនេះ។

## II. ស្ថានភាពទូទៅនៃសិទ្ធិមនុស្សនៅប្រទេសកម្ពុជា

៦. នៅក្នុងរយៈពេលនៃឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យនេះ យើងបានកត់សម្គាល់ឃើញមានវិវឌ្ឍន៍នយោបាយសំខាន់ៗមួយចំនួន។ ចាប់ផ្តើមពីការបោះឆ្នោតថ្នាក់មូលដ្ឋាននៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ និងបានបញ្ចប់នៅពេលដែលប្រទេសនេះបានបោះជំហានចូលក្នុងការបោះឆ្នោតជាតិ (ជ្រើសរើសតំណាងរាស្ត្រ) នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨។ ការបោះឆ្នោតឃុំ-*សង្កាត់* ត្រូវបានប្រព្រឹត្តទៅប្រកបដោយសណ្តាប់ធ្នាប់ល្អ និងសន្តិវិធី ដោយមានប្រជាពលរដ្ឋចំនួន ៩០ ភាគរយចូលរួមការបោះឆ្នោត។ ជាអកុសល ព្រឹត្តិការណ៍ដែលបានកើតឡើងជាបន្តបន្ទាប់មកទៀតបានបង្ហាញថាលទ្ធផលនៃការបោះឆ្នោតទាំងនេះត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំង បើទោះបីជាវាមានអនុលោមភាពស្របតាមច្បាប់ថ្មីក៏ដោយ។ អតីតប្រធានគណបក្សប្រឆាំងដ៏សំខាន់មួយគឺ លោក កឹម សុខា ត្រូវបានឃុំខ្លួនកាលពីខែកញ្ញា ពីបទចោទទាក់ទងនឹងអំពើក្បត់ជាតិ។ នៅថ្ងៃទី១៦ ខែវិច្ឆិកា តុលាការកំពូលបានចេញសាលដីកាបង្គាប់ឲ្យរំលាយគណបក្សសង្គ្រោះជាតិ និងហាមឃាត់សមាជិកជាន់ខ្ពស់ ១១៨ នាក់ មិនឲ្យធ្វើសកម្មភាពនយោបាយរយៈពេល ៥ ឆ្នាំ។ អាសនៈរបស់គណបក្សសង្គ្រោះជាតិនៅក្នុងរដ្ឋសភា និងក្នុងមុខតំណែងនៅថ្នាក់ឃុំ ត្រូវបានបែងចែកទៅឲ្យគណបក្សដទៃទៀត ហើយដែលភាគច្រើនបានទៅគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកំពុងកាន់អំណាច។

៧. ស្ថានភាពនយោបាយនៅតែបន្តមានផលប៉ះពាល់ដល់កិច្ចការពារ និងការលើកកម្ពស់សិទ្ធិមនុស្សគ្រប់រូបនៅក្នុងប្រទេស។ អ្នកការពារសិទ្ធិមនុស្សប្រឈមមហាន្តរាយជាពិសេសនៅក្នុងឆ្នាំនៃការប្រារព្ធខួបលើកទីម្ភៃនៃការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុមបុគ្គល និងអង្គការសង្គម ដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល (សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស)។ ជាពិសេស មានលិខិតមួយពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ តម្រូវឲ្យអង្គការមិនមែន រដ្ឋាភិបាលនានាធ្វើការជូនដំណឹងជាមុនចំនួនបីថ្ងៃដល់អាជ្ញាធរ មុនការរៀបចំពិធី ឬព្រឹត្តិការណ៍ណាមួយ។ រដ្ឋាភិបាលបានបញ្ជាក់ថាការជូនដំណឹងជាមុននេះគឺធ្វើឡើងដើម្បីផ្តល់ការសម្រប-សម្រួលសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ការកំណត់នេះមិនមានចែងនៅក្នុងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬច្បាប់ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឡើយ។ នគរបាលតាមឃ្លាំមើលជាប្រព័ន្ធលើសកម្មភាពរៀបចំកម្មវិធីនានារបស់សង្គមស៊ីវិល។ រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណស្ថានីយ៍វិទ្យុឯករាជ្យមួយចំនួន ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យត្រូវបិទទ្វារដោយសារតែវិក្កយបត្រត្រូវបង់ពន្ធមានទឹកប្រាក់ច្រើនពេក ហើយអ្នកសារព័ត៌មានឯករាជ្យត្រូវបានចោទប្រកាន់ពីបទ "ចារកម្ម"។ នៅខែឧសភា ឆ្នាំ២០១៨ ប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័ត។ ប្រកាសនេះ សំដៅទប់ស្កាត់ការបោះពុម្ពផ្សាយ ឬព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ៊ីនធឺណិតផ្អែកលើហេតុផលទូលំទូលាយខ្លាំងដូចជា "ការបង្កចលាចលចេតនា" ឬ "ការធ្វើឲ្យប៉ះពាល់ដល់ សេដ្ឋកិច្ចជាតិ" ឬ "វប្បធម៌ប្រពៃណី"។

៨. នៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាអន្តរកម្មជាមួយភាគីរដ្ឋនានា និងអ្នកពាក់ព័ន្ធដទៃទៀត នាសម័យប្រជុំលើកទីសាមសិបប្រាំមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រដ្ឋជាច្រើនបានអញ្ជើញ អ្នករាយការណ៍ពិសេសឲ្យយកចិត្តទុកដាក់ជាពិសេសទៅលើផលប៉ះពាល់ផ្អែកសិទ្ធិមនុស្ស ដោយសារស្ថានភាពនយោបាយមុនការបោះឆ្នោតជាតិ

ឆ្នាំ ២០១៨ នៅប្រទេសកម្ពុជា។ របាយ-ការណ៍នេះ ត្រូវបានធ្វើបញ្ចប់ និងបានរៀបចំបញ្ជូននៅក្នុងរយៈពេលមុនកាលបរិច្ឆេទនៃការ បោះឆ្នោតជាតិនេះ។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសវិភាគអំពីផលប៉ះពាល់នៃការបោះឆ្នោត និងដំណើរការបោះឆ្នោត ទៅលើសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន នៅក្នុងអត្ថបទភ្ជាប់បន្ថែម។

៩. ប្រទេសកម្ពុជានៅតែជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ យោងតាមការប៉ាន់ប្រមាណនាពេលបច្ចុប្បន្ន ប្រទេសនេះបានរក្សាអត្រាកំណើនសេដ្ឋកិច្ចជិត ៧ ភាគរយ ដែលទំនងជានឹងបន្តមានយ៉ាងហោចណាស់ក្នុងរយៈពេលពីរឆ្នាំទៅមុខទៀត។ ក្រោយឆ្នាំ ២០១៤ រដ្ឋាភិបាលមិនបានអនុម័តយល់ព្រមលើតួលេខណាមួយឡើយ។

១០. រដ្ឋាភិបាលបានប្ដេជ្ញាតាក់តែងបញ្ចប់ការធ្វើមូលដ្ឋានូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឲ្យបាននៅចុងឆ្នាំ២០១៨។ យើងឃើញមានភ័ស្តុតាងអំពីវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវសិទ្ធិនិងសេរីភាពពាក់ព័ន្ធមួយចំនួន។ ឧទាហរណ៍ កំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់ប្រទេសនេះបានផ្ដល់ធនធានដើម្បីលើកកម្ពស់កិច្ចគាំពារសង្គម និងលទ្ធភាពទទួលបានការអប់រំ ការងារសមរម្យ និងតំហែទាំសុខភាព។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមានជាមួយគោលដៅទី ១៦។

១១. របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពបានទទួលស្គាល់យ៉ាងច្បាស់ថាការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ទាំងពីរនេះ គឺជាបុរេលក្ខខណ្ឌ និងជាលទ្ធផល សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលការណ៍ស្ដីពីការមិនទុកមនុស្សណាម្នាក់ចោលគឺប្រហែលជាការគូសបញ្ជាក់ច្បាស់លាស់បំផុតដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងខាងលើនេះ។ ជាការពិត ការគោរពសិទ្ធិមនុស្សគឺជាផ្នែកដ៏សំខាន់មួយនៃការធានាការអភិវឌ្ឍ និងសន្តិភាពជាយូរអង្វែងនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំកន្លងមកនេះ ទាំងនៅក្នុងអំឡុងពេលនៃកិច្ចជំនួបប្រជុំ និងតាមរយៈការដាក់បញ្ជូនឯកសារផ្លូវការ រដ្ឋមន្ត្រីរបស់រដ្ឋាភិបាលបានធ្វើការឆ្លើយតបទៅអ្នករាយការណ៍ពិសេសថាការផ្ដល់អាទិភាពលើសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ ជាជាងឲ្យអាទិភាពទៅលើសិទ្ធិមនុស្ស។ ការគោរពសិទ្ធិ និងសេរីភាពគឺមានចែងនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ហើយកម្ពុជាក៏បានផ្ដល់សច្ចាប័នស្ទើរតែគ្រប់សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗទាំងអស់។ គេមិនអាចគោរពដោយអន្លើៗ ឬធ្វើមិនដឹងមិនឮដោយអន្លើៗ ទៅលើសិទ្ធិមនុស្សឡើយ ហើយសិទ្ធិមនុស្សទាំងនោះក៏មិនត្រូវយកមកធ្វើជាការបូជាលះបង់ឡើយ។ សន្តិភាពដោយគ្មានយុត្តិធម៌គឺគ្មានចីរភាព រីឯការអភិវឌ្ឍដោយគ្មានសេរីភាព គឺមានន័យថាទុកប្រជាជនចោល ។

១២. នៅក្នុងអំឡុងឆ្នាំ២០១៧-២០១៨ រដ្ឋាភិបាលកម្ពុជាបានបោះពុម្ពផ្សាយសេចក្តីថ្លែងការណ៍មួយចំនួនសំដៅ "ធ្វើការស្រាយបំភ្លឺ និងបង្កើតកំណត់ត្រាដោយផ្ទាល់" លើបញ្ហាផ្សេងៗពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ រដ្ឋាភិបាលបានរិះគន់អង្គការសហប្រជាជាតិជាទូទៅ និងរិះគន់អ្នករាយការណ៍ពិសេសនានា ដោយគ្មានមូលដ្ឋាននៃភស្តុតាងណាមួយឡើយ។ អ្នករាយការណ៍ពិសេស បានឆ្លើយតបទៅនឹងការរិះគន់ទាំងនេះដោយផ្ទាល់ទៅកាន់រដ្ឋាភិបាល ហើយអំពាវនាវឲ្យរដ្ឋាភិបាលដកការរិះគន់នេះចេញពីឯកសារផ្សព្វផ្សាយនិងសេចក្តីថ្លែងការណ៍ផ្លូវការនានា និងធ្វើយ៉ាងណាមិនត្រូវឲ្យករណីនេះកើតមានជាថ្មីទៀតឡើយ។ សកម្មភាពបែបនេះអាចជួយលើកកម្ពស់កិច្ចសន្ទនាស្តីពីបញ្ហាសិទ្ធិមនុស្ស ឲ្យមានលក្ខណៈស្ថាបនា និងប្រកបដោយអត្ថន័យ។

## III. បច្ចុប្បន្នភាពលើអនុសាសន៍នានាដែលបានលើកឡើងនៅក្នុងរបាយការណ៍លើកមុន

១៣. អ្នករាយការណ៍ពិសេសបានធ្វើអនុសាសន៍ជាបន្តបន្ទាប់នៅក្នុងរបាយការណ៍មុនៗ។ ដើម្បីរក្សាឲ្យមានកិច្ចសន្ទនាមួយរដ្ឋាភិបាល លោកស្រីពិនិត្យមើលអនុសាសន៍ដែលខ្លួនបានធ្វើឡើងនៅក្នុងរបាយការណ៍លើកមុន និងដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស (សូមមើលរបាយ-ការណ៍លេខ A/HRC/៣៦/៦១ កថាខ័ណ្ឌទី៦៨) ដែលមានសេចក្តីដូចតទៅ៖

(ក) យើងបានទទួលដំណឹងថាមានការពិភាក្សានាពេលថ្មីៗនេះ ស្តីពីការអនុវត្តអនុសាសន៍ដែលបានលើកឡើងក្នុងការពិនិត្យជាសកលតាមកាលកំណត់ ហើយនឹងមានការផ្តោតលើការរៀបចំរបាយការណ៍បន្ទាប់លើកទីបីរបស់ប្រទេសកម្ពុជា ដែលនឹងត្រូវដល់កាលកំណត់សម្រាប់ការពិនិត្យនៅដើមឆ្នាំ ២០១៩។ អ្នករាយការណ៍ពិសេសស្វាគមន៍ចំពោះការរៀបចំបញ្ជូនក្នុងឆ្នាំនេះ នូវរបាយការណ៍សរុបបញ្ចូលគ្នាចាប់ពីរបាយការណ៍តាមកាលកំណត់លើកទីដប់បួន ដល់ទី ដប់-ប្រាំមួយ ទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ និងរបាយការណ៍តាមកាលកំណត់លើកទីប្រាំមួយ ទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី។

(ខ) ផែនការធ្វើមូលដ្ឋានូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបានស្នើឡើងនឹងត្រូវធ្វើបញ្ចប់នៅចុងត្រីមាសទី២ នៃឆ្នាំ២០១៨។ ទោះជាយ៉ាងណាក៏ដោយ នាកិច្ចប្រជុំនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ គណៈកម្មាធិការថ្នាក់ជាតិ បានស្នើឲ្យមានការពិនិត្យឡើងវិញ និងកាត់បន្ថយចំនួនសូចនាករ។ ក្នុងតំណាក់កាលបច្ចុប្បន្ន ការអនុម័តរបស់គណៈរដ្ឋមន្ត្រីត្រូវបានគ្រោងធ្វើនៅត្រីមាសទី៣ ឆ្នាំ២០១៨។ ផែនការសកម្មភាពមួយសម្រាប់ធានាសន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ (គោលដៅទី១៦) ដែលបរិយាយអំពីសូចនាករដ៏ទូលំទូលាយដើម្បីវាស់ស្ទង់សមិទ្ធផល អាចនឹងគាំទ្រដល់ការងាររបស់ក្រសួងនានា (ឧទាហរណ៍ ក្រសួងយុត្តិធម៌) ក្នុងការពង្រឹងឯករាជ្យភាពរបស់តុលាការ ជាដើម។ ផែនការធ្វើមូលដ្ឋានូបនីយកម្ម គួររាប់បញ្ចូលផងដែរនូវផែនការសកម្មភាពសម្រាប់កាត់បន្ថយភាពក្រីក្រ (គោលដៅទី១) ធានាសុខភាពនិងសុខុមាលភាព (គោលដៅទី៣) ធានានូវការងារពេញលេញ និងផលិតភាពសម្រាប់ទាំងអស់គ្នា (គោលដៅទី៧) ការដោះស្រាយសន្តិសុខស្បៀងនិងទឹកស្អាត (គោលដៅទី២ និងទី៦) និងកាត់បន្ថយវិសមភាព (គោលដៅទី១០) ។ គោលដៅទាំងនេះគឺជាគន្លឹះសម្រាប់ការការពារអ្នកដែលបាត់បង់ឱកាស និងលើកកម្ពស់ការអនុវត្តសិទ្ធិនិងសេរីភាពរបស់ពួកគេ។

(គ) ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍នៅដដែលមិនមានការផ្លាស់ប្តូរ។ អ្នករាយការណ៍ពិសេសលើកទឹកចិត្តឲ្យមានការពិភាក្សាបន្ថែមទៀត អំពីការធ្វើឲ្យដំណើរការនេះប្រសើរថែមទៀត និងពន្លឿនការទទួលស្គាល់ក្រុមជនជាតិដើមភាគតិច និងការទាមទារដីធ្លីរបស់ពួកគេ។

(ឃ) ប្រាក់ប្រដាប់ក្តីនៅមិនទាន់បានបិទបង្ហាញជាសាធារណៈនៅក្នុងតុលាការទាំងអស់ ដោយសារក្រសួងយុត្តិធម៌អះអាងថាខ្លួនកំពុងតែរៀបចំធ្វើបញ្ចប់បញ្ជីប្រាក់ប្រដាប់ក្តីនេះ។

(ង) សេចក្តីជូនដំណឹងថាមិនត្រូវបង់ប្រាក់ឲ្យទៅបុគ្គលិកបំរើការងារក្នុងពន្ធនាគារ មិនត្រូវបានបិទបង្ហាញនៅតាមគ្រប់មណ្ឌលឃុំឃាំងនៅឡើយ។ ប័ណ្ណព័ត៌មានរូបភាពស្តីពីសិទ្ធិរបស់ជនជាប់ឃុំត្រូវបានចែកចាយប៉ុន្តែមិនត្រូវបានបិទផ្សាយនៅគ្រប់មណ្ឌលឃុំឃាំងឡើយ (ហើយមណ្ឌលឃុំ-ឃាំងខ្លះមានបិទប័ណ្ណព័ត៌មានរូបភាពនោះជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ) ។

(ច) ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ពន្ធនាគារបន្តត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ អ្នករាយការណ៍ពិសេសរំលឹករដ្ឋាភិបាលថាការជំនុំជម្រះដោយយុត្តិធម៌ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេលមួយសមហេតុផលបន្ទាប់ការចាប់ខ្លួនដំបូង។ បញ្ហានេះសំខាន់ណាស់ នៅពេលដែលមានមនុស្សត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ដោយសារមានការកើនឡើងខ្លាំងនូវចំនួនជនជាប់ឃុំច្រើនលើសចំណុះនៅក្នុងពន្ធនាគារ (មួយផ្នែកដោយសារយុទ្ធនាការ

ប្រឆាំងគ្រឿងញៀន) អ្នករាយការណ៍ពិសេសជំរុញឲ្យរដ្ឋាភិបាលពិចារណាឡើងវិញអំពីផែនការបង្កើនការប្រើប្រាស់ទោសជំនួសឲ្យការឃុំខ្លួន នៅក្នុងស្ថានភាពមួយចំនួនណា ដែលខ្លួនយល់ឃើញថាមានលក្ខណៈសមស្រប។ អ្នករាយការណ៍ពិសេសក៏បានលើកទឹកចិត្តផងដែរឲ្យរាជរដ្ឋាភិបាលលើកកម្ពស់ការប្រើប្រាស់ទម្រង់ឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធានាឲ្យចៅក្រមធ្វើការឆ្លុះបញ្ចាំងឲ្យបានសមស្របថាតើការឃុំខ្លួនបណ្តោះអាសន្នសមស្របដែរឬទេ (មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា ការឃុំខ្លួនបណ្តោះអាសន្ន គួរតែធ្វើក្នុងករណីពិសេស)។

(ឆ) អ្នកការពារសិទ្ធិមនុស្សមួយចំនួនត្រូវបានដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាពួកគេស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្តី ចំណែកឯអ្នកការពារសិទ្ធិមនុស្សមួយចំនួនទៀតត្រូវបន្តឃុំខ្លួនបណ្តោះអាសន្ន។ ទន្ទឹមនឹងស្វាគមន៍ការដោះលែងអតីតសមាជិកប្រាំរូបនៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក) ក្នុងខែមិថុនា ឆ្នាំ២០១៧ អ្នករាយការណ៍ពិសេសបានបញ្ជាក់ជាថ្មីនូវការអំពាវនាវរបស់អ្នកស្រី សូមឲ្យទម្លាក់ចោលជាស្ថាពរនូវការចោទប្រកាន់ទៅលើអ្នកទាំងនោះ។ នេះគឺជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុចំពោះការចោទប្រកាន់ដែលព្យួរទុកដោយគ្មានពេលកំណត់ ហើយដែលទំនងជាដំណើរការឡើងវិញជាថ្មីនៅពេលណាមួយ។ ជាអាទិ៍ មានករណីលេចធ្លោរជាងគេផ្សេងទៀត រាប់ទាំងករណីអ្នកស្រី ទេព វន្នី (ចោទប្រកាន់ក្នុងឆ្នាំ២០១៣ ត្រូវបានដំណើរការឡើងវិញជាថ្មី ក្នុងឆ្នាំ២០១៧ ដោយមានការចាប់ខ្លួន ការផ្តន្ទាទោស និងការដាក់ពន្ធនាគារ) និង លោក ញឹក ប៊ុនឆៃ (ចោទប្រកាន់ក្នុងឆ្នាំ២០០៧ ដំណើរការឡើងវិញជាថ្មីក្នុងឆ្នាំ២០១៧ ដោយមានការចាប់ខ្លួនក្នុងខែសីហា ហើត្រូវបានដោះលែងក្រោមការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងខែឧសភា ឆ្នាំ២០១៨)។

(ជ) វិធានការលើបរិយាកាសសិទ្ធិមនុស្សនៅជុំវិញការបោះឆ្នោត ត្រូវបានគូសបញ្ជាក់ខាងក្រោមនិងនៅក្នុងអត្ថបទភ្ជាប់បន្ថែម។ ក្នុងរយៈពេលបច្ចុប្បន្ន យើងមានការព្រួយបារម្ភអំពីការគំរាមកំហែង ការចាប់ខ្លួន និងសកម្មភាពបំភិតបំភ័យផ្សេងៗ។

១៤. ចំពោះអនុសាសន៍ដែលមាននៅក្នុងកថាខ័ណ្ឌទី ៦៩ នៃរបាយការណ៍លើកមុនរបស់លោកស្រី៖

(ក) ការងារនៅតែត្រូវបន្តធ្វើលើការពង្រឹងយន្តការតុលាការ ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរមនុស្ស។ ការព្រួយបារម្ភនៅតែបន្តលើកឡើងចំពោះការប្រព្រឹត្តរបស់មន្ត្រីអនុវត្តច្បាប់ទៅលើជនរងគ្រោះជាស្ត្រី ដោយរួមបញ្ចូលទាំងករណីរំលោភសេពសន្ថវៈ ការបៀតបៀន និងឃាតកម្ម។

(ខ) ការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានរារាំងដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃនាខែតុលា ឆ្នាំ២០១៧ ដូចមានរៀបរាប់ខាងលើ។ ដោយមិនគិតពីចេតនាពិតប្រាកដ សេចក្តីណែនាំនេះត្រូវបានយកទៅអនុវត្តក្នុងន័យតម្រូវឲ្យមានការអនុញ្ញាតនិងការដាក់ការរឹតត្បិតទៅលើការប្រមូលផ្តុំដោយសន្តិវិធី ការបណ្តុះបណ្តាល និងការជួបប្រជុំផ្សេងៗ។ បទប្បញ្ញត្តិដូចនេះមិនត្រូវបានចែងនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬ ច្បាប់ស្តីពីសហជីព ឡើយ។

(គ) បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ បាននិងកំពុងត្រូវគេប្រើប្រាស់ ដើម្បីរារាំងសេរីភាពក្នុងការបញ្ចេញមតិ និងការជជែកពិភាក្សា រួមទាំងបទប្បញ្ញត្តិស្តីពីសន្តិជ្ឈិភាពផង។ វិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌដែលបានធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ២០១៨ មានការប្រើប្រាស់ពាក្យពេចន៍ក្នុងន័យទូលាយ ហើយត្រូវការឲ្យមានការប្រើប្រាស់ភាសាដែលច្បាស់លាស់ជាងនេះបន្ថែមទៀត ដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិ និងជៀសវាងហានិភ័យដល់សេរីភាពក្នុងការបញ្ចេញមតិ។ វិស័យដែលជាកង្វល់ រួមមានបទប្បញ្ញត្តិស្តីពីការប្រមាថចំពោះអង្គព្រះមហាក្សត្រ និង លក្ខខណ្ឌសម្រាប់គណបក្ស និងបុគ្គលផ្សេងៗ ដែលតម្រូវឲ្យ"តម្កល់ផលប្រយោជន៍ជាតិជាធំ" និងប្រឆាំង "ការជ្រៀតជ្រែកពីបរទេស"។

(ឃ) សាលាដំបូងចំនួនដប់ប្រាំមួយ ត្រូវបានដំឡើងឲ្យមានប្រព័ន្ធមូលដ្ឋានទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក៏ដោយ នៅមិនទាន់មានការរីកចម្រើនណាមួយលើការផ្សព្វផ្សាយសេចក្តីសម្រេច ឬលើការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីលក្ខខណ្ឌតម្រូវខាងភ័ស្តុតាងនៅឡើយ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ប្រចាំប្រទេសកម្ពុជា ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ចំនួនពីរលើកសម្រាប់ចៅក្រម ដោយផ្តោតលើការបង្ហាញសំអាងហេតុផ្លូវច្បាប់សម្រាប់ការចេញសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

(ង) នៅបន្តមានការឃុំខ្លួនប្រជាពលរដ្ឋមួយចំនួនដោយមិនស្ម័គ្រចិត្តនៅក្នុងមជ្ឈមណ្ឌល "សំចត" ដែលរួមមានមជ្ឈមណ្ឌលព្រៃស្តី។ ទោះយ៉ាងណាក៏ដោយ ចំនួនមនុស្សដែលត្រូវបានឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលនេះដោយសារការចោទប្រកាន់ថាពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀននៅតែ បន្តកើនឡើង។ អគារថ្មីៗមួយចំនួន ត្រូវបាន និងកំពុងសាងសង់នៅខេត្តកណ្តាលដើម្បីស្តារនីតិសម្បទាអ្នកដែលមានពិការភាពផ្លូវចិត្ត ប៉ុន្តែអគារទាំងនោះមិនទាន់ត្រូវបានបើកឲ្យដំណើរការនៅឡើយទេ។

## IV. ក្រុមងាយរងគ្រោះ និងការរើសអើង

១៥. សិទ្ធិមនុស្សអន្តរជាតិ ត្រូវបានកំណត់ដោយឈរលើគោលការណ៍ដែលថាមនុស្សគ្រប់រូបអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសង្គមទាំងអស់ តែងមានក្រុមមនុស្សដែលគេមិនសូវយកចិត្តទុកដាក់ ហើយក៏មានករណីប៉ះពាល់ក្នុងលក្ខណៈណាមួយទៅលើការប្រើប្រាស់សិទ្ធិនិងសេរីភាពរបស់ពួកគេផងដែរ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី ១០ សំដៅកាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងរវាងប្រទេសផ្សេងៗ។ ច្បាប់អន្តរជាតិកំណត់យ៉ាងច្បាស់ថាសិទ្ធិនិងសេរីភាព គួរតែត្រូវបានប្រើប្រាស់ដោយមិនមានការប្រកាន់បែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិសាសន៍ ឬសង្គម ទ្រព្យសម្បត្តិ ប្រភេទនៃកំណើត ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ពិការភាព ឬស្ថានភាពដទៃទៀតឡើយ។ នៅក្នុងរបាយការណ៍របស់លោកស្រី (A/HRC/33/62 និង A/HRC/36/61) អ្នករាយការណ៍ពិសេស បានពិនិត្យពិចារណាទៅលើស្ថានភាពជនជាតិដើមភាគតិច ស្ត្រី ជនជាប់ឃុំ ជនដែលស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ ក្រុមជនជាតិភាគតិច និងកុមារ។ នៅខែសីហា ឆ្នាំ២០១៧ បេសកកម្មរបស់លោកស្រី បានផ្តោតបន្ថែមទៅលើកុមារងាយរងគ្រោះ (កុមាររស់នៅតាមមណ្ឌលស្ថាប័ននានា និងកុមារដែលត្រូវបានជួញដូរ)។ នៅក្នុងផ្នែកនេះ អ្នករាយការណ៍ពិសេស បង្ហាញពីរបកគំហើញ និងព័ត៌មានថ្មីៗស្តីពីក្រុមងាយរងគ្រោះនៅប្រទេសកម្ពុជា។ ការពិនិត្យពិចារណាទៅលើក្រុមដែលងាយរងគ្រោះ គឺពិតជាមានសារៈសំខាន់ជាពិសេស នៅពេលដែលរដ្ឋាភិបាលបាននិងកំពុងស្ថិតក្នុងដំណាក់កាលសរសេរបញ្ចប់នូវផែនការធ្វើមូលដ្ឋានូបនីយកម្មសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីធានាថាគ្មានមនុស្សណាម្នាក់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេទុកចោលឡើយ។

### ក. កុមារ

១៦. ប្រទេសកម្ពុជាមានប្រជាពលរដ្ឋវ័យក្មេង បាននិងកំពុងកើនច្រើនឡើងៗ ហើយប្រជាជនកាន់តែចល័តថែមទៀត។ កុមារងាយរងគ្រោះជាពិសេស នៅពេលដែលនៅវ័យក្មេង ហើយជារឿយៗត្រូវទទួលរងគុណវិបត្តិដោយសារស្ថានភាពសព្វបែបយ៉ាងកើតឡើងពីការមិនសូវបានគេយកចិត្តទុកដាក់។ ការពឹងអាស្រ័យគ្នា និងការទំនាក់ទំនងគ្នាទៅវិញទៅមកនៃសិទ្ធិ មានន័យថា ការប្រើប្រាស់សិទ្ធិរបស់កុមារជារឿយៗតែងត្រូវបានផ្សារភ្ជាប់

ទៅនឹងការប្រើប្រាស់សិទ្ធិរបស់អ្នកដែលមើលថែពួកគេដោយផ្ទាល់។ ហេតុដូច្នេះហើយ កុមារទាំងឡាយដែលឪពុកម្តាយរបស់ពួកគេប្រឈមនឹងហានិភ័យត្រូវបានគេទុកចោល នោះកុមារទាំងនេះនឹងងាយរងគ្រោះជាពិសេស។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយរបាយការណ៍បូកបញ្ចូលគ្នារបស់កម្ពុជារាប់ចាប់ពីរបាយការណ៍លើកទីបួន ដល់ របាយការណ៍លើកទីប្រាំមួយ ត្រូវដល់ពេលកំណត់នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨ ហើយដែលកម្ពុជាមិនទាន់បានដាក់បញ្ជូនទៅគណៈកម្មាធិការសិទ្ធិកុមារនៅឡើយទេ។

១៧. ការអប់រំពាក់ព័ន្ធជាពិសេសដល់កុមារ និងដល់ការអភិវឌ្ឍន៍របស់ពួកគេ។ របាយការណ៍លើកមុនៗ (A/HRC/30/58 និង A/HRC/27/70) បានលើកឡើងអំពីវឌ្ឍនភាពក្នុងវិស័យអប់រំ។ ការអប់រំបាននិងកំពុងមានភាពងាយស្រួល និងអាចរកបានសម្រាប់កុមារទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡាបន្តវិនិយោគលើវិស័យអប់រំនៅទូទាំងប្រទេស ហើយធ្វើការដើម្បីលុបបំបាត់អំពើពុករលួយ ដូចជាការលុបបំបាត់ការលួចចម្លង និងអំពើមិនប្រក្រតីពាក់ព័ន្ធនឹងការប្រឡងបញ្ចប់ការសិក្សាជាដើម។

១៨. ក្រសួងបានរាយការណ៍ពីវឌ្ឍនភាពឆ្ពោះទៅរកការធានាឲ្យមានសមភាពយេនឌ័រ មិនត្រឹមតែក្នុងការចុះឈ្មោះចូលរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការបញ្ចប់ការសិក្សាផងដែរ។ ក្រៅពីសមភាពយេនឌ័រ កុមារមួយចំនួនកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ដោយសារត្រូវគេទុកចោលដោយមូលហេតុជាតិពិន្ទុ ឬពិការភាព។ ទន្ទឹមនឹងមានវឌ្ឍនភាពខាងការដាក់ឲ្យប្រើប្រាស់ផែនការសកម្មភាពអប់រំ ពហុភាសា អ្នករាយការណ៍ពិសេសនៅបន្តបង្ហាញពីក្តីបារម្ភចំពោះស្ថានភាពកុមារមកពីក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច រាប់ទាំងកុមារដែលមានដើមកំណើតពីខ្សែស្រឡាយជនជាតិវៀតណាម ដែលនៅតែបន្តទទួលរងផលវិបាកទាក់ទងនឹង ភាពអាចរកបានលទ្ធភាពទទួលបាន ភាពអាចទទួលយកបាន និងភាពអាចសម្រួលបាន ក្នុងវិស័យអប់រំ។ តាមព័ត៌មានទទួលបានថាកុមារត្រូវបានគេបដិសេធមិនឲ្យចូលរៀនដោយសារតែខ្វះឯកសារផ្លូវច្បាប់មួយចំនួនពីឪពុកម្តាយរបស់ពួកគេដែលជានិគមជនជាតិវៀតណាម ឬការដកហូតឯកសារទាំងឡាយ ដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៩។ ទាក់ទងនឹងការអប់រំ និងសុខភាព វាច្បាស់ណាស់ដែលថា កុមារដែលមានពិការភាពមិនទទួលបានលទ្ធភាពស្មើគ្នាក្នុងការទទួលបានទំនិញ សេវា ឬសម្ភារនិងបរិក្ខារឡើយ។ ឧទាហរណ៍ លទ្ធភាពងាយស្រួលជាក់ស្តែងក្នុងការចូលទៅក្នុងអគារផ្សេងៗ ហើយនិងព័ត៌មានផ្សេងៗជាភាសាសញ្ញា និងអក្សរស្ទាប នៅតែចោទជាបញ្ហាដដែល។

១៩. កិច្ចគាំពារសុខភាពមាតា និងកុមារ មានសារៈសំខាន់ណាស់ចំពោះការលូតលាស់របស់កុមារ។ គំនិតផ្តួចផ្តើមកិច្ចគាំពារសង្គមថ្មី និងគម្រោងសាកល្បងត្រូវបានពិភាក្សាខាងក្រោមនេះ។ ក្រសួងសុខាភិបាល បាននិងកំពុងធ្វើការនៅថ្នាក់ឃុំ-សង្កាត់ នៅទូទាំងប្រទេស ដើម្បីធានាថា លទ្ធភាពទទួលបានកិច្ចគាំពារសុខភាពជាចម្បងអាចរកបានសម្រាប់ទាំងអស់គ្នា។ អត្រាមរណ-ភាពរបស់កុមារនិងទារក បន្តថយចុះ ការឆ្លងរាលដាលក្នុងតំបន់នៃជម្ងឺកញ្ជ្រិលត្រូវបានលុបបំបាត់ទាំងស្រុងនៅកម្ពុជា ការប្រើប្រាស់វិធីព្យាបាលបង្ការការចម្លងមេរោគមេរោគហ៊ីវ/ជំងឺអេដស៍ពីមាតាទៅទារក នៅក្នុងអំឡុងពេលសំរាលកូន ហើយនិងមូលនិធិសមធម៌សុខាភិបាល ជួយធានាដល់ការទទួលបានកិច្ចគាំពារសុខភាពដោយឥតគិតថ្លៃសម្រាប់គ្រួសារក្រីក្របំផុត រួមទាំងកូនៗរបស់ពួកគេ។ រដ្ឋាភិបាលបានចាប់ផ្តើមផងដែរនូវកម្មវិធីចាក់ថ្នាំសម្រាប់កុមារីដើម្បីបង្ការវីរុសបង្ករោគមហារីកស្បូន។ ទោះជាយ៉ាងណាក៏ដោយ កង្វះអាហារូបត្ថម្ភសម្រាប់កុមារ ជាពិសេសនៅតំបន់ជនបទ នៅតែជាកង្វល់នៅឡើយ។

២០. ធានាថាកុមារទាំងអស់ ត្រូវបានចុះបញ្ជីនៅពេលចាប់កំណើត គឺជាកត្តាសំខាន់ក្នុងការទទួលស្គាល់សិទ្ធិរបស់កុមារ។ ក្នុងករណីនេះ ការដកចេញក្នុងឆ្នាំ២០១៧ នូវថ្លៃចុះបញ្ជីកំណើតរហូតដល់រយៈពេល៣០ ថ្ងៃបន្ទាប់ពីថ្ងៃកំណើត ត្រូវបានស្វាគមន៍។

២១. ខណៈពេលដែលមិនទាន់មានប្រព័ន្ធគ្រប់ជ្រុងជ្រោយសម្រាប់ការពារកុមារ និងគ្មានបុគ្គលិកសង្គមកិច្ចនៅថ្នាក់ឃុំ/សង្កាត់ ឬថ្នាក់ស្រុក/ខណ្ឌ ករណីនៃការរំលោភបំពាន និងការមិនយកចិត្តទុកដាក់លើកុមារ មិនត្រូវបានគេ

តាមដាន និងរាយការណ៍ឡើយ។ គណៈកម្មាធិការឃុំ-សង្កាត់ ដើម្បីស្ត្រីនិងកុមារ មានសារៈសំខាន់ ក្នុងសមត្ថភាពរបស់ពួកគេ នៅថ្នាក់មូលដ្ឋាន។ ទោះបីជាមានការបណ្ដុះបណ្ដាលសមាជិកគណៈកម្មាធិការនេះក្ដី ក៏អ្នករាយការណ៍ពិសេសមានកង្វល់ថា ការបណ្ដុះបណ្ដាលនេះអាចមិនគ្រប់គ្រាន់ ដើម្បីផ្ដល់កិច្ចគាំពារដែលមានលក្ខណៈគ្រប់គ្រាន់ អាចទទួលយកបាន និងផ្ដោតលើលទ្ធភាពសម្របខ្លួនដល់កុមារបានឡើយ។

២២. ជាពិសេស មានកុមារច្រើនទៀត ត្រូវបានទុកឲ្យនៅជាមួយសាច់ញាតិដែលមានវ័យចាស់ជរា នៅពេលដែលឪពុកម្ដាយរបស់ពួកគេ ក្លាយជាពលករចំណាកស្រុក ផ្លាស់ទៅធ្វើការនៅតាម រោងចក្រ ឬការដ្ឋានសំណង់នៅក្នុងប្រទេសកម្ពុជា ឬស្វែងរកការងារធ្វើនៅឯក្រៅប្រទេស។ ព័ត៌មានដែលទទួលបានបង្ហាញឲ្យឃើញពីភាពងាយរងគ្រោះខ្ពស់ចំពោះកុមារមួយចំនួនក្នុងចំណោមកុមារទាំងនេះ៖ កុមារខ្លះត្រូវបានគេធ្វើបាប អ្នកខ្លះទៀតធ្លាក់ខ្លួនប្រើប្រាស់គ្រឿងញៀន និងសារធាតុផ្សេងៗ ហើយកុមារខ្លះទៀតនៅទីបំផុតក្លាយជាកុមារស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ។ កុមារដែលទទួលរងការរំលោភបំពានផ្លូវកាយ ឬផ្លូវចិត្តសង្គម នៅក្នុងសហគមន៍ ឬក្នុងក្រុមគ្រួសារ ជាញឹកញាប់ពុំមានមធ្យោបាយស្វែងរកការជួយឧបត្ថម្ភ ឬមានសុវត្ថិភាពឡើយ។ ការស្ទង់មតិស្ដីពីអំពើហិង្សាលើកុមារ និងផែនការសកម្មភាពរបស់រដ្ឋាភិបាល គឺជាជំហានមួយក្នុងទិសដៅត្រឹមត្រូវ ប៉ុន្តែជនរងគ្រោះដោយអំពើហិង្សាជាញឹកញាប់បំផុតតែងតែរស់នៅក្នុងគ្រួសារតែមួយជាមួយជនល្មើស ហើយជនល្មើសមិនត្រូវបាននាំខ្លួនទៅតុលាការ ដើម្បីផ្ដន្ទាទោសតាមច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឡើយ។

២៣. ប្រទេសកម្ពុជាមានកុមារជាច្រើនបាននិងកំពុងរស់នៅក្នុងទីតាំងមជ្ឈមណ្ឌល។ កិច្ចខិតខំប្រឹងប្រែង ដើម្បីរឹតបន្តឹង "ទេសចរណ៍ក្មេងកំព្រា" បានទទួលជោគជ័យ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបច្ចុប្បន្ននេះបាននិងកំពុងផ្ដោតលើការកាត់បន្ថយចំនួនកុមារដែលស្ថិតនៅក្នុងទីកន្លែងថែទាំទាំងនោះ។ ផែនការសកម្មភាពដើម្បីពង្រឹងការថែទាំកុមារ ក្រោមកិច្ចសហការជាមួយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) អង្គការសង្គមស៊ីវិល និងកម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ សំដៅកាត់បន្ថយមកត្រឹម ៣០ ភាគរយនៃចំនួនកុមារនៅក្នុងមជ្ឈមណ្ឌល នៅក្នុងខេត្តចំនួនប្រាំ ដោយធ្វើសមាហរណកម្មពួកគេទៅក្នុង សហគមន៍។ នេះគឺជាកម្មវិធីសាកល្បងវិជ្ជមានមួយ ដែលតាមរយៈនេះ មេរៀនជាច្រើនសម្រាប់ពេលអនាគតប្រាកដជានឹងកើតមានឡើង។

២៤. ភាពក្រីក្រគឺជាកត្តាមួយដ៏សំខាន់នៅក្នុងចំណោមកុមារជាច្រើនដែលស្ថិតក្នុងការថែទាំនៅតាមមជ្ឈមណ្ឌលទាំងនោះ ក្រោយពេលដែលពួកគេបានចេញស្វែងរកការងារធ្វើ និងត្រូវបានគេជួញដូរ។ អាស្រ័យហេតុនេះ ការងារដែលត្រូវធ្វើដើម្បីរៀបចំឲ្យកុមារឲ្យបានវិលត្រឡប់ទៅរួមរស់ជាមួយក្រុមគ្រួសាររបស់ពួកគេវិញគឺត្រូវដោះស្រាយទៅលើគោលដៅមួយចំនួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចជាការកាត់បន្ថយភាពក្រីក្រ (គោលដៅទី១.២) ការអនុវត្តប្រព័ន្ធការពារសង្គមសមរម្យនៅថ្នាក់ជាតិ (គោលដៅទី ១.៣) និងការលើកកម្ពស់បរិយាប័នសង្គម សេដ្ឋកិច្ច និងនយោបាយសម្រាប់ទាំងអស់គ្នា (គោលដៅទី១០.២)។ កម្មវិធីផ្ដល់អាទិភាពដល់ឧត្តមប្រយោជន៍របស់កុមារគឺជាចំណុចដែលមានសារៈសំខាន់ចាំបាច់។

២៥. មិនមានបណ្ដាញពេញលេញនៃបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាលនៅកម្ពុជាឡើយ។ ជាគោលគំនិត គេគួរមានយ៉ាងហោចណាស់ក៏បុគ្គលិកសង្គមកិច្ចមួយរូបដែរនៅក្នុងឃុំ-សង្កាត់នីមួយៗ ដែលគាំទ្រដោយក្រុមបុគ្គលិកសង្គមកិច្ចនៅថ្នាក់ស្រុក។ កិច្ចការពារ និងការងារស្ដារនីតិ-សម្បទាកុមារភាគច្រើន ត្រូវបានអនុវត្តដោយបុគ្គលិកសង្គមកិច្ច ដែលទទួលបានមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តដល់រដ្ឋាភិបាល ក្នុងការលើកកម្ពស់ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ ដើម្បីពិចារណាទទួលស្គាល់យ៉ាងសកម្ម លើកកម្ពស់ និងគាំទ្រការអប់រំការងារសង្គមកិច្ចនិងកា

លានុវត្តភាពការងារ។ បុគ្គលិកសង្គមកិច្ចដែលបានទទួលការបណ្តុះបណ្តាល អាចធ្វើការងារជាមួយគណៈកម្មាធិការឃុំ-សង្កាត់ដើម្បីស្ត្រីនិងកុមារ នៅក្នុងឃុំ-សង្កាត់ ដើម្បីការពារកាន់តែប្រសើរឡើងថែមទៀតដល់កុមារ និងអ្នកដទៃទៀតដែលងាយរងគ្រោះ។

២៦. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តធ្វើការងាររួមគ្នាលើការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានប្រកាសឲ្យប្រើនៅក្នុងឆ្នាំ២០១៦។ អ្នករាយការណ៍ពិសេសស្វាគមន៍ច្បាប់នេះ ប៉ុន្តែសូមរំឭកដល់រដ្ឋាភិបាលថា ត្រូវយកចិត្តទុកដាក់ ដើម្បីធានាថារដ្ឋាភិបាលអនុវត្តច្បាប់ឲ្យបានសមស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ។ ការណ៍ដែលចាំបាច់នោះ គឺត្រូវផ្តល់ធនធាន ឬថវិកា ពេញលេញដល់ប្រព័ន្ធយុត្តិធម៌អនីតិជន រួមទាំងមជ្ឈមណ្ឌលថ្មីសម្រាប់ការស្តារនីតិសម្បទា ដែលត្រូវស្របតាមបទដ្ឋានពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ដូចជា បទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង)។

២៧. មានសេចក្តីរាយការណ៍ពីការពន្យាពេល ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ពីអាយុរបស់អនីតិជន បន្ទាប់ពីការចាប់ខ្លួន ដើម្បីកំណត់ថាតើពួកគេមានអាយុក្រោម ឬលើសអាយុអប្បបរមាក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ឬថាតើពួកគេពិតជាអនីតិជន ឬនីតិជនវ័យក្មេង។ ចំពោះកុមារដែលជាសាក្សី និងជនរងគ្រោះនៃអំពើល្មើស អ្នករាយការណ៍ពិសេសបានទទួលព័ត៌មានថា មានតែតុលាការចំនួនពីរឬបីប៉ុណ្ណោះដែលមានគ្រឿងឧបករណ៍ចាំបាច់សម្រាប់ធ្វើសម្ភាសន៍ឬសាកសួរ និងប្រព័ន្ធសោតទស្សន៍ ដើម្បីទទួលយកសក្ខីកម្មពីចម្ងាយ។ ដូច្នេះ កុមារអាចប្រឈមហានិភ័យដោយការបង្ហាញខ្លួននៅចំពោះមុខអ្នកដែលគេអះអាងថាជាជនល្មើស ហើយត្រូវទទួលរងភាពរងគ្រោះមួយកម្រិតថែមទៀត។

២៨. អ្នករាយការណ៍ពិសេសនៅតែមានកង្វល់ថាកងកម្លាំងសន្តិសុខ និងក្រុមគ្រួសារនៅតែនាំយកអនីតិជនទៅដាក់នៅក្នុងមជ្ឈមណ្ឌលសំចត និងមជ្ឈមណ្ឌលស្តារនីតិសម្បទា ព្រមទាំង ទីកន្លែងថែទាំផ្សេងៗ។ ខណៈពេលដែលផលវិបាកនៃយុទ្ធនាការប្រឆាំងគ្រឿងញៀនកំពុងកើតមាន មានរបាយការណ៍គួរឲ្យព្រួយបារម្ភថាកុមារដែលមានពិការភាពធ្ងន់ធ្ងរ ត្រូវបានឃុំខ្លួននៅកន្លែងទាំងនេះ បើទោះបីជាពួកគេមិនមានប្រវត្តិញៀនថ្នាំ ឬសារធាតុញៀនក្តី។ ស្ថានភាពនេះ បង្ហាញពីសេចក្តីត្រូវការឲ្យមានប្រព័ន្ធការពារសង្គម និងកុមារដ៏ទូលំទូលាយនៅក្នុងប្រទេសកម្ពុជា និងបុគ្គលិកសង្គមកិច្ចដែលទទួលបានការបណ្តុះបណ្តាលសមស្របនៅក្នុងឃុំ-សង្កាត់ទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ការណ៍នេះក៏លើកឡើងផងដែរពីបញ្ហាការគាំទ្រជ្រុងជ្រោយទៅលើកុមារដែលមានពិការភាព និងគ្រួសាររបស់ពួកគេ។

២៩. មានការសង្ឃឹមថារដ្ឋាភិបាលនឹងដាក់បញ្ចូលវិធីសាស្ត្រផ្អែកលើសិទ្ធិកុមារនៅគ្រប់វិស័យទាំងអស់ដែលទាក់ទងនឹងកុមារ។ កុមារស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ និងនៅតាមទីកន្លែងថែទាំផ្សេងៗ កុមារទេសន្តរប្រវេសន៍ដែលមិនមានគ្រួសារនៅជាមួយ និងកុមារដែលត្រូវបានគេជួញដូរគឺជាប្រភេទកុមារដែលងាយរងគ្រោះខ្លាំង ហើយត្រូវការវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដើម្បីការពារសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ចំពោះអ្នកប្រើប្រាស់គ្រឿងញៀននិងសារធាតុញៀនដែលមិនទាន់ផ្តាច់ភាពញៀនបាន ព្រមទាំងអនីតិជនដែលជាទណ្ឌិត ត្រូវតែដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងដ៏ប្រុងប្រយ័ត្ន និងការគាំទ្រជាបន្ត ដើម្បីធានាឲ្យមានការស្តារសម្បទា និងការធ្វើសមាហរណកម្មពិតប្រាកដ។ វាក៏ជាការចាំបាច់ក្នុងការធានាឲ្យមានការលើកកម្ពស់ការយល់ដឹងស្តីពីសិទ្ធិកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការទាំងអស់។

## ខ. ជនជាតិដើមភាគតិច

៣០. អ្នករាយការណ៍ពិសេសមានសេចក្តីរីករាយ ដោយសម្គាល់ឃើញថាក្រសួងអប់រំ យុវជន និងកីឡា បន្តពង្រឹងការផ្តល់ការអប់រំ រួមទាំង ការអប់រំពីរភាសាសម្រាប់ជនជាតិដើមភាគតិច។ អ្នករាយការណ៍ពិសេសបានសង្កេតឃើញពីការយល់ដឹងមួយនៅតាមក្រសួងមន្ទីរនានាថាជនជាតិដើមភាគតិចនៅតែត្រូវបានគេទុកចោល។ លោកស្រីកត់សម្គាល់ថាការយកចិត្តទុកដាក់ជាក់លាក់ ដើម្បីធានាសិទ្ធិជនជាតិដើមភាគតិចនៅក្នុងគ្រប់ផែនការសកម្មភាព និងប្រតិបត្តិការអន្តរក្រសួង គួរត្រូវធ្វើឡើងដើម្បីរួមចំណែកបានគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនឹងបញ្ហាទាំងឡាយដែលប៉ះពាល់ដល់សិទ្ធិជនជាតិដើមភាគតិច។

៣១. កង្វល់នៅតែមានចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ជនជាតិដើមភាគតិច។ នៅក្នុងខែសីហា ឆ្នាំ២០១៧ អ្នករាយការណ៍ពិសេស បានដឹងអំពីជនជាតិដើមភាគតិចនៅខេត្តបាត់ដំបងដែលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍មិនអាចបន្តទៅមុខបាន ពីព្រោះដីនោះនៅរង់ចាំការបោសសំអាតមីន។ ក្នុងន័យនេះ មានការកត់សម្គាល់ថាកម្ពុជាបានបន្ថែមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពោលគឺគោលដៅទី១៨ ស្តីពីការលុបបំបាត់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

៣២. នៅខេត្តស្ទឹងត្រែងគម្រោងវារីអគ្គិសនីសេសានក្រោម២ បានធ្វើឲ្យជនជាតិដើមភាគតិចពូនងបាត់បង់ផ្ទះសម្បែងរបស់ពួកគេ ហើយភាគច្រើននៃព្រៃអារក្ស និងកន្លែងបញ្ចុះសពរបស់ពួកគេ ទៅជាអាងស្តុកទឹក ធ្វើឲ្យពួកគេប្រឈមនឹងហានិភ័យនៃការបាត់បង់មុខរបរចិញ្ចឹមជីវិត។ នៅក្នុងខេត្តព្រះវិហារ ជនជាតិដើមភាគតិចគួយ ត្រូវក្រុមហ៊ុនស្ករអំពៅធ្វើការឈូសឆាយដីស្រែចំការ និងព្រៃឈើមួយចំនួនរបស់ពួកគេ។ ជនជាតិដើមភាគតិចពូនង និងគួយ បាននិងកំពុងរង់ចាំឲ្យមានការចុះបញ្ជីដីរបស់ពួកគេជាដីសមូហភាព។

៣៣. អ្នករាយការណ៍ពិសេសបានបញ្ជាក់ជាថ្មីនូវអនុសាសន៍របស់លោកស្រីថា រដ្ឋាភិបាលគួរពិនិត្យពិចារណាក្នុងការធ្វើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍មានលក្ខណៈសាមញ្ញ ដើម្បីធ្វើឲ្យវាកាន់តែងាយស្រួល និងមានតំលៃសមរម្យសម្រាប់សហគមន៍ជនជាតិដើមភាគតិច។ គិតត្រឹមខែមិថុនា ឆ្នាំ២០១៨ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចប្រមាណជា ៤៥៥ សហគមន៍នៅកម្ពុជា មានសហគមន៍ចំនួន ១៤១ ត្រូវបានទទួលស្គាល់ជាជនជាតិដើមភាគតិច ដោយក្រសួងអភិវឌ្ឍន៍ជនបទ ដែលក្នុងចំណោមសហគមន៍ទាំងនេះ មានសហគមន៍ចំនួន ១២៨ ត្រូវបានចុះបញ្ជីតាមផ្លូវច្បាប់ដោយក្រសួងមហាផ្ទៃ ដែលក្នុងនោះមានតែ ២៤ សហគមន៍ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព។

## គ. អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន

៣៤. ខណៈដែលប្រទេសកម្ពុជាបានផ្តល់កន្លែងសម្រាប់សិទ្ធិជ្រកកោនដល់អ្នកដែលត្រូវបានតាំងទីលំនៅថ្មីពីកោះណារូ ជនជាតិម៉ុងតាញ៉ាដែលបានស្វែងរកសិទ្ធិជ្រកកោនក្នុងប្រទេសកម្ពុជានៅបន្តមានបញ្ហាដដែល។ នៅខែសីហា អ្នករាយការណ៍ពិសេសបានសម្តែងក្តីកង្វល់អំពីស្ថានភាពរបស់ជនជាតិម៉ុងតាញ៉ា ៣៦ នាក់ ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានទទួលស្វែងរកដំណោះស្រាយមួយនៅក្រៅប្រទេស ផ្អែកលើស្ថានភាពធ្ងន់ធ្ងរទាក់ទងការទាមទារសិទ្ធិជ្រកកោនរបស់ពួកគេ។ រហូតមកទល់ពេលនេះ រដ្ឋាភិបាលកម្ពុជាមិនទាន់បានយល់ព្រមសម្រួលឲ្យពួកគេបានធ្វើដំណើរឆ្លងកាត់ទៅទៅកាន់ប្រទេសទីបីដែលមានសុវត្ថិភាពនៅឡើយទេ ប៉ុន្តែបែរជាបានប្រកាសអំពីផែនការសម្រាប់ការនិរទេសពួកគេត្រឡប់ទៅប្រទេសវៀតណាមវិញនៅខែកញ្ញា។ ប្រទេសកម្ពុជាគួរតែគោរពគោលការណ៍ស្តីពីការមិនបញ្ជូនត្រឡប់ទៅវិញ

ហើយធានាថាគ្មានមនុស្សណាម្នាក់ត្រូវបានគេបង្ខំឲ្យត្រឡប់ទៅកាន់ប្រទេសមួយជាទីដែលពួកគេស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារការធ្វើទុក្ខបុកម្នេញឡើយ។

## ឃ. បុគ្គលដែលស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ

៣៥. ក្នុងខែសីហា ឆ្នាំ២០១៧ អ្នករាយការណ៍ពិសេស មានកង្វល់ជាខ្លាំងបន្ទាប់ពីគាត់បានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលព្រៃស្ពឺ ដោយសារមានមនុស្សប្រមាណជាចំនួន៥៤៤ នាក់ រាប់បញ្ចូលទាំងកុមារចំនួន ៦ នាក់ ផងកំពុងត្រូវបានឃុំខ្លួននៅទីនោះ។ នេះគឺជាការកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីដំណើរទស្សនកិច្ចលើកមុនរបស់លោកស្រី ហើយដែលមួយផ្នែកគឺមកពីយុទ្ធនាការប្រឆាំងគ្រឿងញៀនរបស់រដ្ឋាភិបាល។ យើងមិនឃើញមានភាពប្រសើរឡើងទេនៅក្នុងទីតាំងអគារទាំងនេះ ក្រៅតែមានចំនួនមនុស្សកើនឡើងច្រើនហួសចំណុះ។ ក្រោយខែ សីហា មក អ្នករាយការណ៍ពិសេសបានទទួលព័ត៌មានគួរឲ្យជឿទុកចិត្តបានថាកុមារលែងត្រូវបានគេឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលនេះទៀតហើយ និងទទួលបានព័ត៌មានថាមានការកែលម្អរចនាសម្ព័ន្ធខ្លះ ដូចជាការសាងសង់បន្ទប់ទឹក ដែលមានបំពាក់បណ្ដាញទឹកម៉ាស៊ីន និងការដំឡើងភ្លើងអគ្គិសនី និងកង្ហារពិដាន។

៣៦. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានពន្យល់ថាមជ្ឈមណ្ឌលថ្មីមួយបាននិងកំពុងសាងសង់នៅខេត្តកណ្ដាល ដែលនឹងអាចជួយកាត់បន្ថយភាពចង្អៀតណែននៅមជ្ឈមណ្ឌលព្រៃស្ពឺ ដែលផ្ដល់គ្រឿងបរិក្ខារសមរម្យសម្រាប់ ការថែទាំនិងព្យាបាលបុគ្គលដែលមានពិការភាពផ្លូវចិត្តសង្គម។ មជ្ឈមណ្ឌលនេះនឹងអាចសាងសង់រួចរាល់នៅចុងឆ្នាំ ២០១៨។

៣៧. ទោះជាមានការអះអាងពីអាជ្ញាធរថា អ្នកដែលគេ "ប្រមូល" ត្រូវបានយកមកដាក់នៅក្នុងមណ្ឌលនេះក្នុងរយៈពេលមួយសប្ដាហ៍ ដើម្បីអាចធ្វើការរៀបចំចាត់ចែងឲ្យក្រុមគ្រួសាររបស់ពួកគេមកទទួលយកក្ដី ក៏មនុស្សភាគច្រើនដែលបានជួបជាមួយអ្នករាយការណ៍ពិសេស បានអះអាងថាពួកគាត់ត្រូវជាប់នៅទីនោះរយៈពេលវែងជាងនេះ ហើយមនុស្សជាច្រើន បានអះអាងថាពួកគាត់ត្រូវបានគេដាក់នៅទីនោះផ្ទុយនឹងឆន្ទៈរបស់ខ្លួន។ នេះបង្កើតទៅជាការឃុំខ្លួនដោយបំពាន៖ វាមិនស្របទាំងជាមួយនឹងគោលគំនិតនៃពាក្យថា "សំចត" និង ខ្លឹមសារច្បាប់ឡើយ។ វាច្បាស់ណាស់ថា ក្នុងករណីកុមារ អាជ្ញាធរត្រូវយកចិត្តទុកដាក់កំណត់អត្តសញ្ញាណបុគ្គលនោះ ហើយធ្វើការ ពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណសមាជិកគ្រួសារដែលមានបំណងទទួលយកកុមារនោះ។ ទោះជាយ៉ាងណាក៏ដោយក្នុងករណីផ្សេងទៀត បុគ្គលទាំងឡាយគួរតែបានអនុញ្ញាតឲ្យចាកចេញពីមជ្ឈមណ្ឌលតាមឆន្ទៈ។

៣៨. មានការក្រើនរំឭកដល់រដ្ឋាភិបាលថា ការឃុំខ្លួនបុគ្គលដោយផ្ទុយពីឆន្ទៈរបស់ពួកគេ មានន័យថាមជ្ឈមណ្ឌលសំចតទាំងនោះ ស្ថិតក្នុងនិយមន័យអន្តរជាតិនៃពាក្យមណ្ឌលឃុំឃាំង ហើយ រដ្ឋាភិបាលត្រូវចាត់វិធានការ ដើម្បីធានាថាបទដ្ឋានអប្បបរមាស្ដីពីការប្រព្រឹត្តទៅលើជនជាប់ឃុំ ត្រូវតែបំពេញ។ នេះមានន័យថា ជនជាប់ឃុំត្រូវទទួលបានទឹកស្អាតសម្រាប់ទទួលទាន អាហារដែលមានជីវជាតិគ្រប់គ្រាន់ អនាម័យគ្រប់គ្រាន់ ខ្យល់ចេញចូល និងតំហែទាំសុខភាពគ្រប់គ្រាន់ រួមទាំងការគាំទ្រផ្នែកចិត្តសង្គម ព្រមទាំងសិទ្ធិទទួលការជួបសួរសុខទុក្ខ និងធ្វើទំនាក់ទំនងជាមួយសាច់ញាតិរបស់ពួកគេផងដែរ។ ពិសេសជាងនេះទៅទៀត គឺត្រូវធានាថាគ្មានមនុស្សណាម្នាក់ ត្រូវបានឃុំខ្លួនទាំងបំពានឬចាក់សោរបង្ខាំងទុកក្នុងបន្ទប់ ដោយផ្ទុយពីឆន្ទៈរបស់ពួកគេឡើយ។

៣៩. អ្នករាយការណ៍ពិសេស លើកឡើងជាថ្មីពីការអំពាវនាវឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍នៃ សន្និសីទជាតិស្ដីពីស្ថានភាពអ្នករស់នៅតាមចិញ្ចើមផ្លូវ ដែលបានប្រព្រឹត្តទៅក្នុងឆ្នាំ ២០១៥ និងដើម្បីធានាថាមជ្ឈមណ្ឌលសំចតមិនត្រូវបានប្រើប្រាស់ជាមណ្ឌលឃុំឃាំងឡើយ ផ្ទុយទៅវិញគឺដើម្បីផ្ដល់ការថែទាំ សេវា និងជំនួយចាំបាច់ដល់អ្នកដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តពិតប្រាកដ។ លោកស្រីបាន

ផ្តល់អនុសាសន៍ផងដែរដល់រដ្ឋាភិបាលឲ្យកំណត់អត្តសញ្ញាណបុគ្គលម្នាក់ៗឲ្យបានច្បាស់លាស់ ពិនិត្យជាប្រព័ន្ធនូវមូលដ្ឋានគតិយុត្តសម្រាប់ការឃុំខ្លួន និងធ្វើការដើម្បីធានាឲ្យមានការដោះលែងពួកគេ និងរៀបចំឲ្យពួកគេវិលត្រឡប់ទៅរួមរស់ជាមួយក្រុមគ្រួសារ និងសហគមន៍របស់ពួកគេវិញ រាប់ទាំងការចូលរួមក្នុង កម្មវិធីកិច្ចគាំពារសង្គម និងការចិញ្ចឹមជីវិត។

## ង. អ្នកប្រើប្រាស់គ្រឿងញៀននិងសារធាតុញៀនដែលមិនទាន់ផ្តាច់បាន

៤០. នៅក្នុងខែមករា ឆ្នាំ២០១៧ រដ្ឋាភិបាលបានចាប់ផ្តើមដំណាក់កាលដំបូងនៃយុទ្ធនាការរបស់ខ្លួនប្រឆាំងគ្រឿងញៀន។ បច្ចុប្បន្ន កម្មវិធីនេះ ស្ថិតនៅក្នុងដំណាក់កាលទីពីរ។ ផលវិបាកគួរឲ្យ ព្រួយបារម្ភនោះ គឺការកើនឡើងខ្លាំងនូវចំនួនជនជាប់ឃុំនៅក្នុងពន្ធនាគារ មជ្ឈមណ្ឌលសង្គមកិច្ចនិងមជ្ឈមណ្ឌលបន្សាបគ្រឿងញៀន។ រដ្ឋាភិបាលរាយការណ៍ថា នៅក្នុងឆ្នាំ២០១៧ មានមនុស្ស ១៧,៧៩៥ នាក់ (រួមទាំងស្ត្រី ១,៥៨៤ នាក់) ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន៖ មនុស្សចំនួន ៩,៥៩០ នាក់ (ស្ត្រីចំនួន ១,១១៨ នាក់) ពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀន, មនុស្ស ៧ នាក់ (ក្នុងនោះ ២ នាក់ ជាស្ត្រី) ពាក់ព័ន្ធនឹងការផលិត ឬកែឆ្នៃគ្រឿងញៀន, បុរស ១ នាក់ ពាក់ព័ន្ធនឹងការដាំដុះសារធាតុហាមឃាត់ ហើយមនុស្សចំនួន ៨,១៩៧ នាក់ (ស្ត្រី ៤៦៤ នាក់) ពាក់ព័ន្ធការប្រើប្រាស់គ្រឿងញៀន។ ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០១៨ នគរបាលប្រឆាំងគ្រឿងញៀន បានបង្ក្រាបទល្មើសគ្រឿងញៀនចំនួន ៣,១៩២ ករណី និងបានចាប់ខ្លួនមនុស្សចំនួន ៦,៣៦៧ នាក់ (រួមទាំងស្ត្រី ៥៥៧ នាក់) ។ ក្នុងចំណោមអ្នកទាំងនេះ មានមនុស្សតិចជាងពាក់កណ្តាលត្រូវបានបញ្ជូនទៅព្យាបាល នៅសល់ប៉ុន្មានត្រូវបានបញ្ជូនទៅពន្ធនាគារ។ យោងតាម ស្ថិតិជនជាប់ឃុំតាមពន្ធនាគារ ឆ្នាំ២០១៧ ក្នុងចំណោមជនជាប់ឃុំសរុបចំនួន ២៨,៤១៤ នាក់ មានជនជាប់ឃុំចំនួន ៥១,៧ ភាគរយ ត្រូវបានឃុំខ្លួន ដោយសារបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន។

៤១. ក្នុងអំឡុងឆ្នាំនៃការធ្វើរបាយការណ៍នេះ អ្នករាយការណ៍ពិសេសបានទៅទស្សនាមជ្ឈមណ្ឌលជីវិតថ្មីសម្រាប់ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅខេត្តបន្ទាយមានជ័យ មជ្ឈមណ្ឌលព្រៃស្ពឺ មណ្ឌលអប់រំកែប្រែទី១ និងទី២ និងពន្ធនាគាររាជធានីភ្នំពេញ។ អ្នករាយ-ការណ៍ពិសេសបានសង្កេតឃើញមានមនុស្សជាច្រើនត្រូវបានឃុំខ្លួនដោយសារតែយុទ្ធនាការប្រឆាំងគ្រឿងញៀន។ ស្ថានភាពចង្អៀតណែននៅកន្លែងឃុំឃាំងទាំងនោះគឺជាការរំលោភបំពានលើបទដ្ឋានជាតិកម្ពុជា និងបទដ្ឋានអន្តរជាតិ។ អាហារគ្រប់គ្រាន់ ទឹកស្អាត សម្ភារអនាម័យ ឱកាសហាត់ប្រាណ ខ្យល់ចេញចូលក្នុងបន្ទប់ និងការថែទាំសុខភាព នៅខ្វះខាតនៅឡើយ។ បញ្ហានេះកើតឡើងជាប្រព័ន្ធនៅគ្រប់ទីកន្លែង។ ដោយមើលទៅលើចំនួននៃទីកន្លែងសម្រាប់ដាក់អ្នកប្រើប្រាស់គ្រឿងញៀន អ្នករាយការណ៍ពិសេសបានរំឮករដ្ឋាភិបាលជាថ្មីម្តងទៀតថាប្រសិនជាមានមនុស្សត្រូវបានបង្ខាំងទុកផ្ទុយទៅនឹងឆន្ទៈរបស់ពួកគេ នោះមជ្ឈមណ្ឌលនោះក្លាយទៅជាទីកន្លែង ឃុំខ្លួនតាមព្រឹត្តន័យ ដូចដែលបានកំណត់នៅក្នុងបទដ្ឋានសិទ្ធិមនុស្សដែលកម្ពុជាទទួលយក ហើយក្រុមគ្រួសារ មេធាវី និងអ្នកដទៃ ដែលអាចផ្តល់ការគាំទ្រ គួរតែត្រូវបានអនុញ្ញាតឲ្យចូលជួបសួរសុខទុក្ខអ្នកដែលត្រូវបានគេឃុំខ្លួននោះដោយសេរី។

៤២. នៅក្នុងអំឡុងខែមករា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានជូនដំណឹងទៅអ្នករាយការណ៍ពិសេស ថារដ្ឋាភិបាលបាននិងកំពុងសង់មណ្ឌលស្តារនីតិសម្បទាមួយនៅខេត្តព្រះសីហនុ ដែលអ្នកប្រើប្រាស់សារធាតុញៀនមិនទាន់ផ្តាច់បានចំនួន ២,០០០ នាក់ អាចត្រូវគេបញ្ជូនមកព្យាបាល និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់សេវាធ្វើសមាហរណកម្មជាថ្មីកាន់តែប្រសើរឡើង។ ដើម្បីសម្រេចបានគោលដៅស្តារនីតិសម្បទា វាគឺជារឿងសំខាន់ក្នុងការធានាឲ្យមានការបណ្តុះបណ្តាលនិងការអប់រំគ្រប់គ្រាន់អាចរកបាន ជាពិសេសសម្រាប់មនុស្សវ័យក្មេង ដើម្បីជួយដល់ការធ្វើសមាហរណកម្មប្រកបដោយជោគជ័យនៅក្នុងសហគមន៍។ ការអប់រំ និងការបណ្តុះបណ្តាលសមស្រប គួរតែ

ត្រូវបានផ្តល់ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយការផ្តល់ឱកាសអប់រំ តាមរយៈក្រសួងអប់រំ យុវជន និងកីឡា គួរតែត្រូវបានពិនិត្យពិចារណា។

៤៣. យោងតាមរបាយការណ៍របស់ក្រសួងសុខាភិបាល ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ បច្ចុប្បន្ននេះមានមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ៤១៩ កន្លែងកំពុងផ្តល់ការព្យាបាលតាមសហគមន៍សម្រាប់ការប្រើប្រាស់គ្រឿងញៀននិងការញៀនសារធាតុញៀន។ នេះរួមបញ្ចូលទាំងសេវានៅមន្ទីរពេទ្យជាតិចំនួនពីរ និងមន្ទីរពេទ្យបង្អែកខេត្តចំនួន ២៤ (តំណាងឲ្យ ១០០ ភាគរយ នៃគោលដៅរបស់ក្រសួង)។ លើសពីនេះទៀត មន្ទីរពេទ្យបង្អែកស្រុកចំនួន ៧២ (៨៥ ភាគរយនៃគោលដៅរបស់ក្រសួង) និងមណ្ឌលសុខភាពឃុំចំនួន ៣២១ (២៧ ភាគរយនៃគោលដៅរបស់ក្រសួង) កំពុងផ្តល់សេវាបែបនេះ។ ទន្ទឹមនឹងនេះក៏មានការបណ្តុះបណ្តាលជាមូលដ្ឋានទាក់ទងនឹងការផ្តល់សេវាព្យាបាលនិងការថែរក្សាអ្នកដែលមានជំងឺផ្លូវចិត្ត និងបញ្ហាញៀនគ្រឿងញៀនដែលមិនទាន់ផ្តាច់បាន។

៤៤. ក្រសួងបានសហការផងដែរជាមួយអ្នកឯកទេសអន្តរជាតិ ដើម្បីបណ្តុះបណ្តាលគ្រូបង្គោល ថ្នាក់ជាតិចំនួន ២១ នាក់ ស្តីពីសេវាប្រឹក្សាយោបល់ ការថែទាំ និងការព្យាបាល សម្រាប់អ្នកញៀនគ្រឿងញៀន។ អ្នករាយការណ៍ពិសេសសម្តែងស្វាគមន៍ដល់ផែនការរបស់ក្រសួង ក្នុងការពន្លឿនការងារប្រឹក្សាយោបល់ និងវិធីព្យាបាលដែលមានការទទួលស្គាល់ត្រឹមត្រូវ ដើម្បីកាត់បន្ថយចំណង់ ជាពិសេសចំពេលដែលកំពុងកើតមានអត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំមេតំហ្វេតាមីន។ មជ្ឈមណ្ឌលទាំងនេះគាំទ្រដល់អ្នកញៀនគ្រឿងញៀននៅតាមសហគមន៍។

៤៥. អ្នករាយការណ៍ពិសេស ស្វាគមន៍កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការបំពានគ្រឿងញៀននិងសារធាតុញៀន ដែលបាននិងកំពុងអនុវត្ត តាមរយៈក្រសួងអប់រំ យុវជន និងកីឡា។

## ច. ជនជាប់ឃុំ

៤៦. អត្រាប្រេវ៉ាឡង់នៃការឃុំខ្លួនបណ្តោះអាសន្ន ការខ្វះការប្រើប្រាស់ទោសជំនួសឲ្យការឃុំខ្លួន និងការបន្តយុទ្ធនាការប្រឆាំងគ្រឿងញៀន គួបផ្សំគ្នាបង្កើនជាសម្ពាធលើពន្ធនាគារ។ រដ្ឋាភិបាលកត់សម្គាល់ពីការកើនឡើងនៃចំនួនជនជាប់ឃុំរហូតដល់ ៣៥% នៅចន្លោះ ឆ្នាំ២០១៦ និងឆ្នាំ ២០១៧ ដែលនេះបណ្តាលមកពីគោលនយោបាយប្រឆាំងគ្រឿងញៀន។ ភាពចង្អៀតណែនបានឈានដល់កម្រិតដូចនេះ នៅឯមណ្ឌលឃុំឃាំងមួយចំនួន ដែលជនជាប់ឃុំមិនអាចត្រូវបានរៀបចំឲ្យនៅដោយឡែកតាមប្រភេទសមស្របបាន។ អនីតិជន និងមនុស្សពេញវ័យត្រូវបានដាក់ឲ្យនៅចម្រុះគ្នា។ ស្ថានភាពដូចគ្នាក៏បានកើតមានឡើងចំពោះជនជាប់ឃុំបណ្តោះអាសន្នមុនការជំនុំជម្រះ ហើយនិងទណ្ឌិត។ ស្ថានភាពមានភាពខុសគ្នានៅតាមពន្ធនាគារនីមួយៗ។ ក្រសួងមហាផ្ទៃយល់ដឹងពីបញ្ហានេះ ហើយបញ្ជាក់ថាក្រសួងបាននិងកំពុងធ្វើឲ្យប្រសើរឡើងថែមទៀតដល់លទ្ធភាពប្រើប្រាស់បរិក្ខារនិងទីកន្លែងលម្ហែកម្សាន្ត និងទីធ្លាខាងក្រៅបន្ទប់ឃុំឃាំង។ នៅខែមីនា ឆ្នាំ២០១៨ អ្នករាយការណ៍ពិសេសបានទៅទស្សនាពន្ធនាគាររាជធានីភ្នំពេញ។ បើនិយាយពីចំនួនមនុស្សនៅក្នុងបន្ទប់ឃុំឃាំង ស្ថានភាពនៅទីនោះមានលក្ខណៈល្អប្រសើរគួរឲ្យកត់សម្គាល់ជាងនៅមណ្ឌលអប់រំកែប្រែទី១ និង ទី២។ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ យោងតាមកំណត់ត្រារបស់រដ្ឋាភិបាលមានជនជាប់ឃុំចំនួន ២៨,៨២៩ នាក់ ដែលក្នុងនោះមានតែ ៧,៦៨៤ នាក់ ប៉ុណ្ណោះដែលទទួលបានសាលក្រមស្ថាពរ។ អ្នករាយការណ៍ពិសេស មានកង្វល់ពេលបានដឹងពីគម្រោងសម្រាប់ពន្ធនាគារបង់ប្រាក់ ដោយមានលក្ខខណ្ឌល្អប្រសើរជាងពន្ធនាគារបច្ចុប្បន្ន សម្រាប់ជនជាប់ឃុំដែលមានបំណងចំណាយថវិកាឯកជននៅក្នុងពេលដែលពួកគេត្រូវឃុំខ្លួន។ ជនជាប់ឃុំទាំងអស់ គួរតែមានលក្ខខណ្ឌនៃការឃុំខ្លួនដូចគ្នា លក្ខខណ្ឌដែលត្រូវបំពេញតាម និងលើសពីអ្វីដែលមានចែងក្នុងបទដ្ឋានអប្បបរមា

កំណត់ដោយសន្ធិសញ្ញាផ្សេងៗរបស់អង្គការ សហប្រជាជាតិ ដែលកម្ពុជាទទួលយក ព្រមទាំងគោលការណ៍ណែនាំបន្ថែមផ្សេងៗ។

## ឆ. ជនដែលមានពិការភាព

៤៧. ដោយមានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់រដ្ឋាភិបាល និងដៃគូដែលខ្លួនបានជ្រើសរើសដើម្បីធ្វើការងារបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរដែលបានកើតឡើងលើមនុស្សជាច្រើននៅក្នុងសម័យខ្មែរក្រហមនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងសម័យសង្គ្រាមស៊ីវិល កម្ពុជាគួរតែជាប្រទេសនាំមុខគេនៅក្នុងវិស័យទាក់ទងនឹងសិទ្ធិជនដែលមានពិការភាព។

៤៨. ខណៈដែលអ្នករាយការណ៍ពិសេស ទទួលបានព័ត៌មានអំពីវិធានការវិជ្ជមាន ដើម្បីការពារសិទ្ធិជនដែលមានពិការភាព ការខ្វះខាតទិន្នន័យជាមូលដ្ឋាន ស្តីពីជនដែលមានពិការភាព និងការខ្វះការចងក្រងឯកសារដែលបញ្ជាក់ថាពួកគេជាជនដែលមានពិការភាព ដែលជារឿយៗនាំឲ្យពួកគេជួបឧបសគ្គ ក្នុងការទទួលបានសេវាមួយចំនួនជាក់លាក់។ ជាពិសេស បញ្ហាទាក់ទងនឹងសុខភាព។ របាយការណ៍ស្តីអំពីការរើសអើងនៅសាលារៀន មណ្ឌលសុខភាព និងធនាគារឯកជន បានជំរុញឲ្យមានាការបន្តជាចាំបាច់នូវការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ជនដែលមានពិការភាពនៅក្នុងចំណោមប្រជាពលរដ្ឋទូទៅ។ លទ្ធភាពទទួលបានយុត្តិធម៌ក៏នៅតែជាបញ្ហាប្រឈមសម្រាប់ជនដែលមានពិការភាព មិនថាពួកគេមានឋានៈជាជនរងគ្រោះ ឬត្រូវចោទថាជនល្មើសឡើយ។

## ជ. ស្ត្រី

៤៩. អ្នករាយការណ៍ពិសេស គូសបញ្ជាក់ជាថ្មីអំពីកង្វល់ទៅលើបញ្ហាទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងការបង្វែរទៅរកការសម្រុះសម្រួល សេចក្តីត្រូវការសម្រាប់ការបំបាត់ចោលអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ការអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាំងនេះ បញ្ហាដែលបានលើកឡើងផងដែរដោយគណៈកម្មាធិការការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅក្នុងការពិនិត្យរបាយការណ៍របស់កម្ពុជា (CEDAW/C/KHM/CO/4-5)។ អ្នករាយការណ៍ពិសេស ស្វាគមន៍ព័ត៌មានដែលផ្តល់ដោយក្រសួងកិច្ចការនារីថាចំនួនភាគរយនៃស្ត្រីដែលទទួលរងនូវអំពើហិង្សាពីដៃគូជិតស្និទ្ធរបស់ពួកគេអាចចាកចេញបានកាន់តែច្រើនឡើងពីស្ថានភាពរំលោភបំពានទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីនៅតែមានកង្វល់ចំពោះករណីមួយចំនួនដែលស្ត្រីមានអារម្មណ៍ថាត្រូវគេបង្ខំឲ្យរស់នៅជាមួយអ្នករំលោភបំពាន និងករណីអំពើហិង្សា និងការបំពារបំពានផ្លូវភេទ រួមទាំងការរំលោភសេពសន្ថវៈផងដែរ ដែលមិនមានការដាក់ទោសទណ្ឌ។ ការរំលោភបំពានផ្លូវភេទជាច្រើនរួមទាំងការរំលោភសេពសន្ថវៈដែលគេអះអាងថាមិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសឡើយ។ សំណុំរឿងខ្លះទុកចំហចោលមិនទាន់ត្រូវចាត់ការអស់រយៈពេលបួនទៅប្រាំឆ្នាំក្រោយអង្គហេតុបានកើតឡើង។ ស្ត្រីនៅតែមានការស្ទាក់ស្ទើរក្នុងការរាយការណ៍ពីការរំលោភសេពសន្ថវៈនិងការរំលោភផ្លូវភេទដទៃទៀត។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គឺមិនស្របទាំងស្រុងទៅនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ឡើយ ហើយជាអកុសល ការអនុវត្តច្បាប់នេះនៅតែមានការបង្វែរករណីអំពើហិង្សាក្នុងគ្រួសារទៅជាការសម្រុះសម្រួល ជាពិសេសនៅពេលដែលជនរងគ្រោះស្នើសុំ។ អ្នករាយការណ៍ពិសេសម្តែងស្វាគមន៍ចំពោះការពិតដែលថាក្រសួងកិច្ចការនារី កំពុងចាប់ផ្តើមវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តច្បាប់នេះ ដើម្បីពង្រឹងការអនុវត្តច្បាប់។ ការយាយីផ្លូវភេទ មិនត្រូវបានកំណត់ច្បាស់លាស់នៅក្នុងច្បាប់ ក្រៅតែពីមាត្រា២៥០ នៃក្រមព្រហ្មទណ្ឌ ហើយការយល់ដឹងនៅតែមានកម្រិតទាបនៅឡើយ។

៥០. អ្នករាយការណ៍ពិសេសធ្លាប់បានលើកឡើងអំពីបញ្ហាទាក់ទងនឹងតួនាទីរបស់ស្រ្តីក្នុងកិច្ច-ការនយោបាយ តាមរយៈរបាយការណ៍នាពេលកន្លងមក (សូមមើលរបាយការណ៍ A/HRC/៣៣/៦២, កថាខណ្ឌទី ២២ ហើយនិង របាយការណ៍ A/HRC/៣៦/៦១)។ អ្នករាយការណ៍ពិសេសបានរំឭកដល់រដ្ឋាភិបាលថាមាត្រា ៤ នៃ អនុសញ្ញាស្តីពីការកាត់បន្ថយគ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី អនុញ្ញាតឲ្យមានវិធានការពិសេសបណ្តោះអាសន្ន សំដៅដោះស្រាយនូវអតុល្យ- ភាព។ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី បានផ្តល់អនុសាសន៍ពីរលើកទាក់ទងនឹងវិធានការពិសេសបណ្តោះអាសន្នដើម្បីបង្កើនចំនួនអ្នកតំណាងជាស្ត្រីនៅក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ជាពិសេសក្នុងកិច្ចការនយោបាយ តុលាការ ការបរទេស និងការទូត (សូមមើល របាយការណ៍ CEDAW/C/KHM/CO/៣, កថាខណ្ឌទី ១៤ ហើយនិង របាយការណ៍ CEDAW/C/KHM/CO/៤-៥, កថាខណ្ឌទី ២៩)។ យោងតាមព័ត៌មានទទួលបានដោយអ្នករាយការណ៍ពិសេស នៅត្រឹមខែមិថុនា ឆ្នាំ២០១៨ មានស្ត្រីចំនួន ២០ ភាគរយ ដែលកាន់តួនាទីក្នុងរដ្ឋសភា (មុនការបោះឆ្នោតខែ កក្កដា ឆ្នាំ ២០១៨) និង ចំនួន ១១ ភាគរយ ដែលកាន់តួនាទីក្នុងព្រឹទ្ធសភា (បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា នាខែ កុម្ភៈ ឆ្នាំ ២០១៨)។ យើងមានការកត់សម្គាល់ថាកិច្ចខិតខំប្រឹងប្រែងមួយចំនួននៅក្នុងវិស័យមុខងារសាធារណៈត្រូវបានធ្វើឡើងសំដៅបង្កើនចំនួនស្ត្រីនៅក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្ត។ កិច្ចការទាំងនោះរួមមានការបង្កើនអាយុចូលនិវត្តន៍សម្រាប់ស្ត្រីជាមន្ត្រីរាជការស៊ីវិលស្របតាមគោលការណ៍ស្ម័គ្រចិត្ត ហើយនិងការកំណត់ឲ្យមានចំនួនស្ត្រីពី ២០ ភាគរយ ទៅ ៥០ ភាគរយនៅក្នុងចំណោមមន្ត្រីរាជការស៊ីវិលដែលត្រូវជ្រើសរើសថ្មី។ អ្នករាយការណ៍ពិសេសលើកទឹកចិត្តឲ្យមានការអនុវត្ត និងការពិនិត្យតាមដានចំណុចដៅទាំងនេះ។

៥១. សេចក្តីព្រាងច្បាប់មួយត្រូវបានតាក់តែងបញ្ចប់ក្នុងខែមេសា ឆ្នាំ ២០១៨ ក្នុងន័យប្រឹងប្រែងគ្រប់គ្រងការពារពោះជំនួស និងការផ្តល់កិច្ចការពារដល់ស្ត្រីនិងកុមារ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការពរពោះជំនួសនេះ។ អ្នករាយការណ៍ពិសេសសម្តែងស្វាគមន៍ចំពោះសេចក្តីព្រាងច្បាប់នេះ ដែលត្រូវបានចែករំលែក ហើយលោកស្រីនឹងផ្តល់មតិយោបល់សំដៅធ្វើឲ្យសេចក្តីព្រាងច្បាប់នេះមានលក្ខណៈសមស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

## V. ការពង្រឹងកិច្ចគាំពារសង្គម សុខាភិបាល និងការអប់រំ

៥២. នៅមុនតំណាក់កាលមានផែនការមូលដ្ឋានូបនីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អ្នករាយការណ៍ពិសេសបានបន្តធ្វើការងាររបស់លោកស្រីទាក់ទងនឹងក្រុមប្រជាជនដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ក្នុងគោលបំណងស្វែងយល់ឲ្យបានច្រើនអំពីការកៀរគរមូលនិធិ និងការធ្វើសេក្តីសម្រេចចាត់ថ្នាក់អាទិភាពនៅក្នុងបរិបទនៃការបន្តអនុវត្តសិទ្ធិសេដ្ឋកិច្ច-សង្គមក្នុងប្រទេសកម្ពុជា។ កម្ពុជាកំពុងបន្តមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងខ្លាំង ដែលបាននិងកំពុងបន្តផ្តល់ធនធានសម្រាប់ធ្វើឲ្យកិច្ចគាំពារសង្គម ការទទួលបានការអប់រំ ការងារសមរម្យ និងតំហែទាំសុខភាព មានលក្ខណៈកាន់តែប្រសើរ។ នាខែមីនា ឆ្នាំ ២០១៨ អ្នករាយការណ៍ពិសេសបានជួបប្រជុំជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយលោកស្រីមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះផែនការយុទ្ធសាស្រ្ត ដែលបាននិងកំពុងអនុវត្តសំដៅរធ្វើឲ្យប្រសើរឡើងនូវការរាយការណ៍ផ្នែកថវិកា ហើយនិងការផ្សារភ្ជាប់រវាងសេចក្តីសម្រេចផ្នែកថវិកាទៅនឹងលទ្ធផលរំពឹងទុកដែលមានលក្ខណៈអាចវាស់វែងបាន។ តម្រូវការចាត់ថ្នាក់អាទិភាពទៅលើការវិនិយោគផ្នែកសិទ្ធិមនុស្ស ហើយនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពគួរត្រូវរៀបចំពន្លេចឡើងនៅក្នុងផែនការមូលដ្ឋានូបនីយកម្ម។

៥៣. អ្នករាយការណ៍ពិសេសទទួលបានការលើកទឹកចិត្តតាមរយៈផែនការកសាងមូលនិធិសន្តិសុខសង្គម និង មូលនិធិសុខភាពសង្គម ហើយនិងផែនការរបស់រដ្ឋាភិបាលសំដៅសម្រេចឲ្យបាននូវការទទួលបានតំហែទាំសុខ

ភាពជាសកល។ ចំណាយសាធារណៈកម្រិតទាបទៅលើវិស័យសុខាភិបាលនាពេលកន្លងមក បានផ្តល់ផលវិបាកក្នុងរូបភាពជាបន្ទុកធ្ងន់ធ្ងរដល់អ្នកជំងឺដែលត្រូវរ៉ាប់រងចំណាយផ្នែកសុខភាពដោយខ្លួនឯង។ ការចំណាយព្យាបាលផ្នែកសុខភាពគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងឡាយដែលគ្រួសារនីមួយៗកំពុងជួបប្រទះ ហើយចំណាយប្រភេទនេះគឺជាចំណែកដ៏ធំនៃចំណាយសរុបរួមក្រៅពីចំណាយលើចំណីអាហាររបស់គ្រួសារនៅក្នុងប្រទេសកម្ពុជា។ ថ្វីត្បិតតែចំណាយលើគាំពារទាំសុខភាព និងសន្តិសុខសង្គមគឺជាចំណាយដែលមានតម្លៃថ្លៃក៏ដោយ ក៏ចំណាយទាំងនេះឆ្លុះបញ្ចាំងអំពីការវិនិយោគដ៏មានសារៈសំខាន់ពីសំណាក់រដ្ឋាភិបាលទៅលើប្រជាជនរបស់ខ្លួន។

៥៤. ម្យ៉ាងវិញទៀត យើងឃើញមានគម្រោងសាកល្បងត្រូវបានដាក់ឲ្យអនុវត្តនាពេលថ្មីៗនេះតាមរយៈការផ្ទេរមូលនិធិឲ្យទៅស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបសម្រាលកូនរួច។ ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់ស្ត្រីជាកម្មការនីរោងចក្រផ្នែកវាយនភ័ណ្ឌ (១២០ ភាគរយ នៃប្រាក់បៀវត្ស និងសម្រាប់រយៈពេលបីខែ) គឺជារឿងវិជ្ជមានមួយផងដែរ។ គ្រប់ផែនការ និងយុទ្ធសាស្ត្រទាំងអស់នេះ ទាមទារឲ្យមានការផ្តល់ធនធានបានគ្រប់គ្រាន់ និងការពិនិត្យតាមដានឲ្យបានដិតដល់។ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅលើពិភពលោកដែរ ស្ត្រីមានផ្ទៃពោះនៅបន្តបាត់បង់ការងារដោយមូលហេតុមិនសមស្របមួយចំនួននៅក្នុងពេលដែលគភ៌របស់ស្ត្រីទាំងនោះត្រូវបានមើលឃើញ ឬត្រូវបានជូនដំណឹង។ មូលហេតុ"ផ្លូវការ"ដែលបណ្តាលឲ្យស្ត្រីមានផ្ទៃពោះបាត់បង់ការងារគឺមានលក្ខណៈផ្សេងៗពីគ្នា ប៉ុន្តែលទ្ធផលចុងក្រោយគឺស្ត្រីទាំងនោះបាត់បង់ការងារ និងអត្ថប្រយោជន៍ទាំងឡាយរបស់ពួកគេ ខណៈពេលដែលមាតា និងទារកកំពុងស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ហើយដែលត្រូវយកចិត្តទុកដាក់ជាពិសេសនោះ។

៥៥. ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក៏ដោយ ក៏ប្រជាជនមួយចំនួននៅតែមិនអាចទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ខណៈដែលពួកគេមានប័ណ្ណមូលនិធិសន្តិ-សុខសង្គមសាធារណៈ និងប័ណ្ណមូលនិធិសមធម៌សុខាភិបាលរួចហើយក៏ដោយ។ ប្រជាជនដែលមានពិការភាពក៏ទទួលផលប៉ះពាល់ដូចខាងលើផងដែរ។ អ្នករាយការណ៍ពិសេសលើកទឹកចិត្តឲ្យ រដ្ឋាភិបាលបន្តធ្វើការវិនិយោគលើវិស័យសុខាភិបាល សន្តិសុខសង្គម និងការអប់រំ ហើយបន្តធ្វើការងារអន្តរស្ថាប័ននៅគ្រប់ជាន់ថ្នាក់ទាំងអស់សំដៅធានាថាប្រជាជនកម្ពុជាទាំងឡាយមានសេវាទាំងនេះ និងអាចទទួលបានសេវាដែលមានគុណភាពខ្ពស់ និងមានលក្ខណៈទទួលយកបាន។

## VI. **វិស័យដីធ្លី**

៥៦. យោងតាមតួលេខរបស់រដ្ឋាភិបាលនាខែ ធ្នូ ឆ្នាំ ២០១៧ រដ្ឋាភិបាលបានផ្តល់ប័ណ្ណកម្មសិទ្ធិចំនួន ៤.៨៨១.៥៨២ ក្បាលដី ដែលស្មើនឹង ៦៦,៤ ភាគរយ នៃចំនួនប៉ាន់ស្មានសរុប ៧ លាន ក្បាលដី នៅទូទាំងប្រទេស ហើយរដ្ឋាភិបាលគ្រោងនឹងសម្រេចគោលដៅឲ្យបាន ១០០ ភាគរយនៅឆ្នាំ ២០២៣។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជាបន្តជួបប្រទះនឹងជម្លោះដីធ្លីដែលអូសបន្លាយពេលវេលាយូរអង្វែង ហើយដែលជះឥទ្ធិពលដល់សិទ្ធិជាមូលដ្ឋានរបស់គ្រួសារ និងសហគមន៍ដែលរងផលប៉ះពាល់ទាំងនោះ។

៥៧. ទោះបីជាមានយន្តការដោះស្រាយជម្លោះនៅតាមក្រសួងផ្សេងៗគ្នាក៏ដោយក៏ស្ថាប័នរដ្ឋនានាបន្តធ្វើការងារដាច់ដោយឡែកពីគ្នា ដោយមិនមាននីតិវិធីប្រកបដោយតម្លាភាព ឬមានលក្ខណៈចូលរួមពីគ្រប់ភាគីឡើយ ហើយរបៀបដោះស្រាយជម្លោះដីធ្លី និងការផ្តល់សំណងទៀតសោតក៏មិនមានលក្ខខណ្ឌតម្រូវអប្បបរមាដែលធានាបាននូវភាពត្រឹមត្រូវដែរ។ ទោះជាជម្លោះមួយចំនួនត្រូវបានដោះស្រាយរួចហើយក៏ដោយ (ដូចជាជម្លោះដីធ្លីទាក់ទងនឹងសម្បទានដីចម្ការអំពៅក្នុងខេត្តកោះកុង) ក៏ជម្លោះដីធ្លីផ្សេងៗទៀតទាក់ទងនឹងសម្បទានដីចម្ការអំពៅនៅខេត្តកំពង់ស្ពឺ ព្រះវិហារ កោះកុង និងឧត្តរមានជ័យ នៅតែមិនទាន់ទទួលបានដំណោះស្រាយនៅឡើយ។ រដ្ឋាភិបាលអះអាងថាជម្លោះទាំងនេះបាននិងកំពុងត្រូវដោះស្រាយស្របតាមច្បាប់មានលក្ខណៈអាចទទួលបានព័ត៌មានគ្រប់គ្រាន់

មានតម្លាភាព អាចព្យាករបាន និងដោយគោរពដល់សិទ្ធិផ្សេងៗ។ អ្នករាយការណ៍ពិសេសកត់សម្គាល់ឃើញថា ដំណើរការដោះស្រាយជម្លោះដីធ្លីជាមួយក្រុមហ៊ុនស្ករអំពៅ មិនគោរពបាននូវគោលការណ៍តម្លាភាព នីត្យានុកូលភាព ភាពអាចទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ភាពអាចព្យាករបាន សមភាព និងការគោរពនូវសិទ្ធិផ្សេងៗទេនោះ ហានិភ័យទាក់ទងនឹងទំនាស់ និងភាពចលាចលនៅតែបន្តមានដដែល។

៥៨. អ្នករាយការណ៍ពិសេសសូមគូសបញ្ជាក់អំពីតម្រូវការគោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មី ប្រកបដោយភាពប្រទាក់ក្រឡាសម្រាប់ប្រទេសកម្ពុជាដោយរួមបញ្ចូលទាំងវិធានការធានាការផ្តល់សំណងសម្រាប់ការធ្វើអស្សាមិករណ៍ឬការដកហូតយកដីធ្លី ការតម្រូវឲ្យមានការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍ និងតំណាងរបស់ពួកគេ ព្រមទាំងអង្គការសង្គមស៊ីវិលផ្សេងៗ។ កង្វះខាតគោលនយោបាយនេះ បណ្តាលឲ្យកើតមានស្ថានភាពបច្ចុប្បន្នមួយដែលក្នុងនោះករណីភាគច្រើននៃកាតព្វកិច្ចមូលដ្ឋានទាក់ទងនឹងផ្លូវច្បាប់ និងកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សត្រូវបានមើលរំលង ហើយការកសាងសំណុំឯកសារ ការចេញសេចក្តីណែនាំ និងការអនុវត្តតាមបែបអភិក្រមគ្រប់ជ្រុងជ្រោយ ជារឿយៗតែងមានការខ្វះខាត ដែលជាហេតុបណ្តាលឲ្យកើតមានផលប៉ះពាល់អវិជ្ជមានទៅលើជីវភាពរបស់គ្រួសារ និងសហគមន៍ដែលត្រូវបានបន្លាស់ទីទាំងនោះ។ អ្នករាយការណ៍ពិសេសសូមគូសបញ្ជាក់អំពីតម្រូវការទាក់ទងការវាយតម្លៃដោយឯករាជ្យទៅលើតំបន់តាំងលំនៅជាថ្មីទាំងនោះនៅក្នុងប្រទេសកម្ពុជា ស្របតាមទស្សនវិស័យសំដៅធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទាំងនោះ។

៥៩. ក្នុងអំឡុងពេលនៃបេសកកម្មខែ មីនា ឆ្នាំ ២០១៨ អ្នករាយការណ៍ពិសេសបានទទួលព័ត៌មានថាសមាជិកនៃកម្លាំងប្រដាប់អាវុធបានប្រើប្រាស់អាវុធបាញ់ទៅលើអ្នកតវ៉ា ហើយបានបំផ្លាញទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងជម្រករបស់ពួកគេនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១៨ នៅស្រុកស្នួល ខេត្តក្រចេះ។ ឧប្បត្តិហេតុនេះកើតឡើងដោយមានការជាប់ពាក់ព័ន្ធនឹងករណីជម្លោះដីធ្លីមួយ និងការចរចាដោះស្រាយការតាំងទីលំនៅជាថ្មីរវាងសហគមន៍ក្រុមហ៊ុនចំការកៅស៊ូមេមត់ ហើយនិងក្រុមការងារដោះស្រាយជម្លោះដីធ្លីខេត្តក្រចេះ។ អ្នករាយការណ៍ពិសេសបានតាមដានករណីនេះយ៉ាងយកចិត្តទុកដាក់ ហើយបានបង្ហាញក្តីបារម្ភដោយផ្ទាល់ទៅកាន់មន្ត្រីរដ្ឋាភិបាលក្នុងពេលកិច្ច-ប្រជុំនានា រួមទាំងទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផងដែរ។ ករណីចលាចលនៅខេត្តក្រចេះនេះគូសបញ្ជាក់អំពីសារៈសំខាន់នៃការយល់ដឹង និងការដោះស្រាយឫសគល់នៃបញ្ហា ដែលបណ្តាលឲ្យកើតមានករណីតវ៉ាទាំងឡាយ។ ឫសគល់នៃបញ្ហាទាំងនេះដែលជារឿយៗមានជាប់ពាក់ព័ន្ធនឹងការបដិសេធមិនអនុវត្តសិទ្ធិមនុស្សត្រូវតែដោះស្រាយឲ្យបានត្រឹមត្រូវ ក្នុងករណីយើងចង់រក្សាឲ្យមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ អ្នករាយការណ៍ពិសេសមានការសោកស្តាយនៅពេលដែលអ្នកសង្កេតការណ៍របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងសង្គមស៊ីវិល ត្រូវបានរារាំងមិនឲ្យចូលទៅក្នុងតំបន់ដែលកើតមានការផ្ទុះអាវុធ។ ក្នុងន័យលើកកម្ពស់សេចក្តីទុកចិត្ត និងតម្លាភាព អ្នករាយការណ៍ពិសេសជឿជាក់ថាវាគឺជារឿងសំខាន់ដែលត្រូវអនុញ្ញាតឲ្យអ្នកឃ្លាំមើលឯករាជ្យចូលទៅកាន់តំបន់នោះ។

៦០. នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៨ សិក្ខាសាលាពិគ្រោះយោបាលថ្នាក់ជាតិលើកទីប្រាំពីរ ស្តីពីសេចក្តីព្រាងច្បាប់លើកទីដប់ នៃក្រមបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗ។ ដំណើរការតាក់តែងក្រមនេះអូសបន្លាយអស់រយៈពេលយ៉ាងយូរ ប៉ុន្តែពោរពេញទៅដោយការចូលរួម។ ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៧ ក្រោយពេលដែលនាយករដ្ឋមន្ត្រីថ្លែងបញ្ជាតាមរយៈសុន្ទរកថាជាសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសផ្អាកដំណើការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម។ សេក្តីព្រាងច្បាប់នេះទទួលបានការជំទាស់ពីក្រុមកសិករ និងអង្គការមិនមែនរដ្ឋាភិបាល ដោយមូលហេតុថាវាមានការរឹតត្បិតទៅលើសិទ្ធិរបស់កសិករតូចតាច។

## VII. ការវាយតម្លៃទៅលើ ″លំហប្រជាធិបតេយ្យ″

៦១. នៅក្នុងរយៈពេលនៃឆ្នាំធ្វើរបាយការណ៍នេះ ករណីនៃការអនុវត្តច្បាប់នានាដែលមាន សរសេរនៅក្នុងរបាយការណ៍របស់លោកស្រី (សូមមើលរបាយការណ៍ A/HRC/៣៣/៦២, កថាខណ្ឌទី ២៨-៣៤) គួបផ្សំនឹងច្បាប់និងបទបញ្ញាថ្មីៗ នៅតែចោទជាបញ្ហាដដែល សម្រាប់អ្នករាយការណ៍ពិសេស។ ចំនួននៃការប្រើប្រាស់ច្បាប់ទាំងនោះមានការកើនឡើងដែលមិនធ្លាប់មានពីមុនមកក្នុងប្រទេសកម្ពុជា ហើយដែលមានគោលដៅរឹតត្បិតការសម្តែងមតិដោយសេរី និងមតិនយោបាយជំទាស់។ បទចោទនានាទាក់ទងនឹងការធ្វើកុប្បកម្ម ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ការសូកប៉ាន់ ការបរិហារកេរ្តិ៍ ការក្លែងបន្លំឯកសារ និងសន្ទិដ្ឋិភាពជាមួយបរទេស ត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ តាមរយៈការចោទប្រកាន់ទៅលើសំឡេងឯករាជ្យឬសំឡេងជំទាស់ (ដោយរួមទាំងអ្នកកាសែត និងតំណាងអង្គការមិនមែនរដ្ឋាភិបាល) ឬការឃុំខ្លួនពួកគេ។ ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលមានភាពអព្យាក្រឹតផ្នែកនយោបាយ កំពុងចោទជាបញ្ហាច្រើនឡើងៗ ខណៈពេលដែលសកម្មភាពជាច្រើនដែលត្រូវបានគេគិតថាជាសកម្មភាពរិះគន់រដ្ឋាភិបាលត្រូវបានចាត់ទុកថាជាសកម្មភាព″នយោបាយ″ទៅវិញ។

៦២. តាមរយៈលិខិតចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៧ ដែលផ្ញើទៅកាន់អាជ្ញាធរថ្នាក់ក្រោមជាតិ ហើយដែលមានរៀបរាប់ក្នុងផ្នែកខាងលើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានគូសបញ្ជាក់ថាអង្គការសង្គមស៊ីវិលត្រូវបានតម្រូវឲ្យជូនដំណឹងទៅអាជ្ញាធរឃុំ និងស្រុក ក្នុងរយៈពេលបីថ្ងៃមុនរៀបចំសកម្មភាពទាំងអស់ ដោយរួមបញ្ចូលទាំងសកម្មភាពអប់រំ និង បណ្តុះបណ្តាលផងដែរ។ លក្ខខណ្ឌតម្រូវឲ្យមានការរាយការណ៍អំពីសកម្មភាពខាងលើហាក់ដូចជាធ្វើឡើងផ្ទុយពីច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងសេចក្តីណែនាំស្តីពីការអនុវត្តច្បាប់នេះ។ ទោះជារដ្ឋាភិបាលអះអាងថាការរាយការណ៍មានភាពចាំបាច់ដើម្បីធានាសុវត្ថិភាពដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងដើម្បីសម្រួលដល់ការៀបចំវគ្គបណ្តុះបណ្តាលក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាយល់ឃើញថាលក្ខខណ្ឌតម្រូវនេះគឺជាទម្រង់មួយនៃការត្រួតពិនិត្យតាមដាន និងគ្រប់គ្រង ដែលមានលក្ខណៈបែបបំពាន។

៦៣. ការធ្វើវិសោធនកម្មនាពេលថ្មីៗនេះទៅលើក្រមព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញ ដោយរួមបញ្ចូលទាំងការរៀបចំនិងអនុវត្តបទប្បញ្ញត្តិស្តីពីការប្រមាថចំពោះអង្គព្រះមហាក្សត្រ បានត្រួសត្រាយផ្លូវសម្រាប់ការកាត់បន្ថយសេរីភាពបន្ថែមទៀត។ ការដាក់ឲ្យអនុវត្តប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីធឺណិតនៅព្រះរាជាណាចក្រកម្ពុជា ក្នុង ខែ ឧសភា ឆ្នាំ ២០១៨ ដូចមានរៀបរាប់ខាងលើ បានបង្កើនការឃ្លាំមើលទៅលើប្រព័ន្ធអ៊ីធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ខណៈដែលគណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីថ្លែងការណ៍ក្នុងខែតែមួយទាក់ទងនឹងតួនាទីនិងភារកិច្ចរបស់អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ហើយដែលសេចក្តីថ្លែងការណ៍នោះរួមបញ្ចូលការរឹតត្បិតជាទូទៅទៅលើសេរីភាពនៃការសម្តែងមតិ ដែលហួសព្រំដែនអនុញ្ញាតដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ រីឯក្នុងការអនុវត្តជាក់ស្តែងវិញ វិធានការតាមផ្លូវតុលាការត្រូវបានបន្តប្រើប្រាស់ប្រឆាំងនឹងប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងមតិយោបល់ដែលបញ្ចេញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។

៦៤. ការកាត់បន្ថយសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយក៏នៅបន្តមាននៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៧ សារព័ត៌មាន the Cambodia Daily ត្រូវទទួលរងការវាយតម្លៃឡើងវិញលើការបង់ពន្ធ ដែលតាមរយៈនោះសារព័ត៌មានេះត្រូវជំពាក់ប្រាក់ពន្ធសរុបប្រហាក់ប្រហែលស្មើនឹង ៦,៣ លាន ដុល្លាសហរដ្ឋអាមេរិក។ ប្រាក់ជំពាក់ពន្ធនេះត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃ ហើយវារួមបញ្ចូលនូវប្រាក់ជំពាក់ពន្ធសរុប និងការប្រាក់។ ដោយសារអាជ្ញាបណ្ណមិនត្រូវបានបន្តសារព័ត៌មាននេះសម្រេចបោះពុម្ពផ្សាយអត្ថបទសារព័ត៌មានលេខចុង

ក្រោយរបស់ខ្លួននៅថ្ងៃទី ៤ ខែ កញ្ញា ហើយក៏បានបិទបញ្ចប់សារព័ត៌មានដែលបានធ្វើសេចក្តីរាយការណ៍ដោយឯករាជ្យអស់ រយៈពេល ២៤ ឆ្នាំ កន្លងមក។ ស្ថានីយផ្សាយវិទ្យុចំនួន ១៩ ត្រូវបានបិទចាប់តាំងពីខែ សីហា ឆ្នាំ ២០១៧។ វិទ្យុគឺជាប្រភពផ្តល់ព័ត៌មានដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ ការរឹតត្បិតទាំងឡាយទៅលើការផ្តល់អាជ្ញាបណ្ណ ឬ ទៅលើការទទួលបានហ្វ្រេកង់ផ្សាយ គឺចៀសមិនផុតឡើយពីការរឹតត្បិតសេរីភាពរបស់ប្រជាជនកម្ពុជាក្នុងការទទួលបានព័ត៌មាន។

៦៥. អ្នករាយការណ៍ពិសេសបានលើកឡើងអំពីករណីជាច្រើនទៅកាន់រដ្ឋាភិបាល ដោយយល់ឃើញថាករណីទាំងនោះអាចបង្កើតឲ្យមានបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យដែលជះឥទ្ធិពលអវិជ្ជមានទៅលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់អ្នកដទៃ បង្កើតឲ្យមានការត្រួតពិនិត្យជាមុនដោយខ្លួនឯងលើការបោះពុម្ពផ្សាយ ហើយនិងរារាំងមិនឲ្យមានការជជែកវែកញែកជាសាធារណៈប្រកបដោយភាពច្នៃប្រឌិតនិងការទទួលខុសត្រូវទាក់ទងនឹងប្រធានបទដែលបម្រើដល់ផលប្រយោជន៍សាធារណៈ។ ករណីទាំងនេះមានលក្ខណៈធ្ងន់ធ្ងរជាពិសេសក្នុងកាលៈទេសៈនៃការបោះឆ្នោតជាតិថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៨។ ការរឹតត្បិតសំឡេងរបស់ប្រជាជនកម្ពុជាអាចបណ្តាលឲ្យមានការគំរាមកំហែងស្ថិរភាពពិតប្រាកដ ដែលរដ្ឋាភិបាល និងប្រជាជនខ្លួនឯងបានខិតខំរួមគ្នាកសាងឡើងយ៉ាងលំបាក។ នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សេរីភាពក្នុងការចូល-រួមបង្កើតសមាគម ក្នុងការសម្តែងមតិ និងក្នុងការជួបប្រជុំដោយសន្តិវិធី គួរត្រូវបានការពារ និងពង្រីកឡើង ជាជាងត្រូវបានរឹតត្បិត។

## VIII. ការចូលរួមក្នុងដំណើរការនយោបាយ

៦៦. អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភអំពីការវិវត្តន៍នានាទាក់ទងនឹងការចូលរួមក្នុងដំណើរការនយោបាយកាលពីឆ្នាំមុន។ ដូចដែលបានធ្វើការកត់សម្គាល់ខាងលើរួចហើយថាការបោះឆ្នោតឃុំ-សង្កាត់បានប្រព្រឹត្តិទៅដោយសន្តិវិធី បើទោះជាមានការរាយការណ៍ថាមានភាពមិនប្រក្រតីខ្លះៗក៏ដោយ ក៏វាបានបង្កើតនូវបទដ្ឋានថ្មីដល់តម្លាភាពក្នុងដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានសេចក្តីរាយការណ៍គួរឲ្យកត់សំគាល់ថា មានការដាក់កំហិតលើគណបក្សនយោបាយនានា និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងការគំរាមកំហែងនិងការបំភិតបំភ័យនៅមុនពេលបោះឆ្នោត។ រដ្ឋសភាបានអនុម័តនូវវិសោធនកម្មច្បាប់មួយចំនួន ដែលប៉ះពាល់ដល់ដំណើរការនយោបាយកាលពីឆ្នាំមុន។ វិសោធនកម្មទាំងនេះត្រូវបានធ្វើឡើងចំពោះច្បាប់ស្តីពីគណបក្សនយោបាយ កាលពីខែមីនា ឆ្នាំ២០១៧ ហើយដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍លើកមុន (សូមមើល A/HRC/36/61, កថាខ័ណ្ឌទី៨)។ អំណាចថ្មីទាំងនេះ ត្រូវបានយកមកប្រើប្រាស់។

៦៧. ស្ថាបនិក និងជាប្រធានគណបក្សអំណាចខ្មែរ លោក សួន សេរីរដ្ឋា ត្រូវបានឃុំខ្លួនក្នុងខែ សីហា ឆ្នាំ ២០១៧ ក្រោយពីបានបង្ហោះសារមួយនៅក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក ដោយធ្វើការរិះគន់ទៅលើការពង្រាយទាហាននៅក្បែរព្រំដែនរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ លោកត្រូវបានផ្តន្ទាទោសពីបទញុះញង់ ដោយទទួលទោសជាប់ពន្ធនាគារចំនួនប្រាំឆ្នាំ។ ប្រធានគណបក្សថ្មី គឺលោក សួង សុភ័ណ្ឌ ត្រូវបានជ្រើសតាំងភ្លាមៗដើម្បីធានាថាគណបក្សនឹងមិនមានលក្ខណៈផ្ទុយពីខ្លឹមសារនៃវិសោធនកម្មថ្មីនៃច្បាប់ស្តីពីគណបក្សនយោបាយឡើយ។ នៅក្នុងខែ សីហា ប្រធានគណបក្សខ្មែររួបរួមជាតិ គឺលោក ញឹក ប៊ុនឆៃ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការចោទប្រកាន់ការផលិតគ្រឿងញៀន ដែលធ្វើឡើងកាលពី១០ឆ្នាំមុន។ លោកធ្លាប់បម្រើការងារជាមេបញ្ជាការមួយរូបនៅក្នុងកងកម្លាំងប្រដាប់អាវុធ ហើយនិងកាន់តួនាទីជាទីប្រឹក្សារដ្ឋាភិបាលរហូតដល់ខែ មិថុនា ឆ្នាំ ២០១៧។ ក្រោយការបោះឆ្នោតថ្ងៃទី ៤ ខែ មិថុនា មេឃុំជាប់ឆ្នោតតែមួយគត់ដែលមិនមែនជាសមាជិកគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គឺជាសមាជិកនៃគណបក្សខ្មែររួបរួមជាតិរបស់គាត់។

លោកត្រូវបានដោះលែងឲ្យនៅក្រៅឃុំប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងខែ ឧសភា ឆ្នាំ២០១៨។

៦៨. ក្នុងខែកក្កដា ឆ្នាំ២០១៧ រដ្ឋសភាបានអនុម័តវិសោធនកម្មម្តងទៀតនៃច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីរារាំងគណបក្សនយោបាយណាដែលមានទំនាក់ទំនង ឬប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម។ គណបក្សណាដែលប្រព្រឹត្តដូចនេះ អាចត្រូវហាមឃាត់មិនឲ្យធ្វើនយោបាយសម្រាប់ រយៈពេល៥ឆ្នាំ ហាមឃាត់មិនឲ្យចូលរួមក្នុងការបោះឆ្នោត ឬក៏ត្រូវរំលាយចោលតែម្តង។

៦៩. ដូចដែលអ្នករាយការណ៍ពិសេសបានរាយការណ៍នៅក្នុងបទបង្ហាញផ្ទាល់មាត់របស់លោកស្រីជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសម័យប្រជុំលើកទី ៣៦ មេដឹកនាំគណបក្សសង្គ្រោះជាតិ គឺលោក កឹម សុខា ត្រូវបានចាប់ខ្លួនពីបទចោទទាក់ទងនឹងការថ្លែងរបស់លោកកាលពីឆ្នាំ២០១៣ អំពីយុទ្ធសាស្រ្តនយោបាយនៅមូលដ្ឋានរបស់លោកដើម្បីតតាំងនឹងរដ្ឋាភិបាលបច្ចុប្បន្ន។ បន្ទាប់មកទៀត លោកត្រូវបានចោទប្រកាន់ពីបទសមគំនិតជាមួយមហាអំណាចបរទេស គឺជាអំពើមួយដែលត្រូវបកស្រាយថា "បង្កអរិភាព ឬជាអំពើឈ្លានពានប្រឆាំងនឹងកម្ពុជា"។ មហាអំណាចបរទេសនៅទីនេះ ត្រូវបានទំលាក់ទៅលើសហរដ្ឋអាមេរិក។ គាត់នៅតែត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលអប់រំកែប្រែ "ម៣"។ អ្នករាយការណ៍ពិសេស មិនត្រូវបានអនុញ្ញាតិឲ្យជួបគាត់ទេកាលពីខែមីនា ឆ្នាំ២០១៨។

៧០. ក្នុងខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីការទទួលបណ្តឹងពីគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស យុវជនកម្ពុជាក្រសួងមហាផ្ទៃបានដាក់សំណើមួយទៅតុលាការកំពូលតាមច្បាប់វិសោធនកម្មថ្មីនៃច្បាប់ស្តីពីគណបក្សនយោបាយដើម្បីរំលាយគណបក្សសង្គ្រោះជាតិ។ ទន្ទឹមនឹងនោះ នៅពេលដែលសំណុំរឿងនេះ កំពុងត្រូវបានពិនិត្យដោយតុលាការ វិសោធនកម្មមួយចំនួនទៀតទាក់ទងនឹងច្បាប់បោះឆ្នោត ត្រូវបានអនុម័ត ដែលមានចែងពីដំណើរការនៃការបែងចែកអាសនៈឡើងវិញរបស់គណបក្សឈ្នះឆ្នោត ដែលត្រូវបានរំលាយ។

៧១. កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូលបានសម្រេចរំលាយគណបក្សសង្គ្រោះ-ជាតិ និងហាមឃាត់សមាជិកជាន់ខ្ពស់ចំនួន១១៨រូប នៃគណបក្សប្រឆាំងពីការធ្វើនយោបាយសម្រាប់រយៈពេល៥ឆ្នាំ។ អ្នករាយការណ៍ពិសេសមានការបារម្ភថាភ័ស្តុតាងនានាដែលផ្តល់ឲ្យដោយក្រសួងមហាផ្ទៃ ហើយដែលតុលាការកំពូលបានយកមកធ្វើជាសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីរំលាយគណបក្សសង្គ្រោះជាតិ គឺជាផ្នែកនៃភ័ស្តុតាងដូចគ្នាដែលកំពុងយកមកប្រើប្រាស់ដោយចៅក្រមស៊ើបសួរដើម្បីចោទប្រកាន់ប្រឆាំងនឹងលោក កឹម សុខា។ សាលដីកាតុលាការកំពូលមិនបានជំទាស់នឹងភ័ស្តុតាងទាំងនោះទេ ហើយក៏មិនមានសារណាការពារពីគណបក្សសង្គ្រោះជាតិផងដែរ ដែលការណ៍នេះបង្កជាកង្វល់យ៉ាងធ្ងន់ធ្ងរ ព្រោះថាភ័ស្តុតាងដែលលើកឡើងនោះគឺជាមូលដ្ឋានឈានដល់ការធ្វើសេចក្តីសម្រេចរំលាយគណបក្សសង្គ្រោះជាតិ។

៧២. សមាជិកគណបក្សសង្គ្រោះជាតិជាច្រើនបានចាកចេញពីប្រទេសចាប់តាំងពីពេលនោះមក ហើយសមាជិកជាច្រើនបានរាយការណ៍ពីការបំភិតបំភ័យដោយអាជ្ញាធរ និងការដាក់សម្ពាធឲ្យ "ចុះចូល" ជាមួយគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។

៧៣. ក្រោយពីគណបក្សត្រូវបានរំលាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការបែងចែកអាសនៈរដ្ឋសភាដែលគណបក្សសង្គ្រោះជាតិទទួលក្រោយការបោះឆ្នោតឆ្នាំ២០១៣។ គណបក្សចំនួនបីបានទទួលយកអាសនៈទាំងនេះ (រួមមានគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសញ្ជាតិកម្ពុជា និងគណបក្សអភិវឌ្ឍន៍សេដ្ឋកិច្ចខ្មែរ)។ គណបក្សចំនួនពីរបានបដិសេធ (រួមមានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សខ្មែរឈប់ក្រ)។ ហេតុដូច្នេះ អាសនៈទាំងនេះក៏ត្រូវបានបែងចែកទៅឲ្យគណបក្សប្រជាជនកម្ពុជា។

៧៤. តំណែងឃុំ/សង្កាត់របស់គណបក្សសង្គ្រោះជាតិ (ជាង៤៣ភាគរយនៃចំនួនសរុប) នៅក្នុងការបោះឆ្នោតឃុំ/សង្កាត់កាលពីខែមិថុនា ឆ្នាំ២០១៧ ក៏ត្រូវបានបែងចែកឡើងវិញ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែរ កាលពីខែធ្នូ ឆ្នាំ២០១៧។ ជាលទ្ធផល គណបក្សប្រជាជនកម្ពុជា បានទទួលយកតំណែងស្ទើរតែទាំងអស់ គឺចំនួន៤.៥៤៨ តំណែង នៃតំណែងក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន៥.០០៧ របស់គណបក្សសង្គ្រោះជាតិ និងកាន់កាប់តំណែងមេឃុំ/ចៅសង្កាត់ទាំងអស់របស់គណបក្សសង្គ្រោះជាតិ ដែលមានចំនួន ៤៨៩ ឃុំ/សង្កាត់។ តំណែងក្រុមប្រឹក្សាឃុំ/សង្កាត់ដែលនៅសេសសល់ ត្រូវបានបែងចែកទៅឲ្យគណបក្សហ៊្វុនស៊ិនប៉ិចចំនួន ២៤០ គណបក្សខ្មែររួបរួមជាតិចំនួន ២០៣ គណបក្សសញ្ជាតិកម្ពុជាចំនួន ១០ គណបក្សយុវជនកម្ពុជាចំនួន ៣ និងគណបក្សប្រជាធិបតេយ្យជនជាតិដើមភាគតិចកម្ពុជា ចំនួន៣។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន បានបដិសេធមិនទទួលយកការបែងចែកនេះទេ។

៧៥. នៅឯព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាចំនួនពីររូបក៏បានបាត់បង់អាសនៈរបស់ពួកគេដែរបន្ទាប់ពីការរំលាយគណបក្សសង្គ្រោះជាតិ។ គណបក្សសង្គ្រោះជាតិមិនបានចូលរួមប្រកួតក្នុងការបោះឆ្នោតឃុំ/សង្កាត់កាលពីឆ្នាំ២០១២នោះទេ ដោយសារតែគណបក្សនេះត្រូវបានបង្កើតក្រោយការបោះឆ្នោតនោះតាមរយៈការច្របាច់បញ្ចូលគ្នារវាងគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ដែលគណបក្សទាំងពីរនេះមានអាសនៈនៅព្រឹទ្ធសភា។ មានតែសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងសមាជិករដ្ឋសភាទេត្រូវចូលរួមនៅក្នុងការបោះឆ្នោតដោយមិនផ្ទាល់នៃសមាជិកព្រឹទ្ធសភានេះមានន័យថាគណបក្សប្រជាជនកម្ពុជា កាន់កាប់ជាង៩៥ភាគរយនៃអាសនៈក្រោយពីការបែងចែកឡើងវិញ។ ការបោះឆ្នោតព្រឹទ្ធសភា ត្រូវរៀបចំប្រព្រឹត្តិទៅនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ដោយ គណបក្សប្រជាជនកម្ពុជាឈ្នះអាសនៈទាំង៥៨កៅអី (អាសនៈចំនួនពីរត្រូវទទួលតាមរយៈការតែងតាំងដោយព្រះមហាក្សត្រ និងពីរទៀតតាមរយៈការបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា)។

៧៦. ផលប៉ះពាល់នៃវិសោធនកម្មច្បាប់ទាំងនេះ និងផលវិបាកនៃការបែងចែកអាសនៈឡើងវិញ គឺជាការដកហូតសិទ្ធិចូលរួមនយោបាយរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើនលាននាក់។ សម្រាប់ប្រជា-ពលរដ្ឋទាំងឡាយណាដែលបានបោះឆ្នោតជូនគណបក្សសង្គ្រោះជាតិ នៅក្នុងមណ្ឌលដែលគណបក្សសង្គ្រោះជាតិឈ្នះ បេក្ខជនដែលពួកគេបានបោះឆ្នោតឲ្យនៅក្នុងការបោះឆ្នោតតំណាង រាស្ត្រឆ្នាំ២០១៣ និងការបោះឆ្នោតឃុំ/សង្កាត់ ឆ្នាំ២០១៧ ត្រូវបានដាក់ជំនួសដោយមនុស្សផ្សេងដែលតំណាងដោយគណបក្សនយោបាយផ្សេងទៅវិញ។ ជាលទ្ធផល វាក៏មានផលប៉ះពាល់ទៅដល់ការបោះឆ្នោតព្រឹទ្ធសភាផងដែរ។ ស្ថានភាពនេះបណ្តាលឲ្យមានកង្វល់យ៉ាងធ្ងន់ធ្ងរអំពីសិទ្ធិចូលរួមក្នុងកិច្ចការនយោបាយ ដែលរួមបញ្ចូលនូវសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួនដោយខ្លួនឯង។

៧៧. អ្នករាយការណ៍ពិសេស កត់សម្គាល់ថា សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបីរូប បានលាលែងពីតំណែង បន្ទាប់ពីការរំលាយគណបក្សសង្គ្រោះជាតិ ដោយសារពួកគេគឺជាសមាជិកដែលត្រូវបានតែងតាំងដោយគណបក្សសង្គ្រោះជាតិ (សមាសភាព នៃគណៈកម្មាធិការនេះ ត្រូវបានបែងចែករវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បន្ទាប់ពីការអនុម័តសេចក្តីសម្រេចស្តីពី"វប្បធម៌សន្ទនា" កាលពីខែកក្កដា ឆ្នាំ២០១៤ ដោយទុកអាសនៈមួយសម្រាប់តំណាងឲ្យសង្គមស៊ីវិល)។ អ្នកទទួលការតែងតាំងថ្មី ដែលការតែងតាំងរបស់ពួកគេហាក់ដូចជាមិនស្របនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការអនុម័តនៅក្នុងខែធ្នូ ដោយសមាជិកដែលជាសមាសភាពថ្មីរបស់រដ្ឋសភា។

៧៨. កម្ពុជាប្រកាសថាខ្លួនប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស (មាត្រា៥១ នៃរដ្ឋធម្មនុញ្ញ)។ នៅថ្ងៃបញ្ចប់នៃរយៈពេលដែលបានពន្យារពេលសម្រាប់ការចុះឈ្មោះគណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជាតិ ខែកក្កដា ឆ្នាំ២០១៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចុះបញ្ជីគណបក្សនយោបាយចំនួន ២០ ដែលភាគច្រើននៃគណបក្សទាំងនោះគឺជាគណបក្សដែលទើបតែបង្កើតថ្មីៗ។ អ្នករាយ

ការណ៍ពិសេស ត្រូវបានគេរំលឹកថា កាលពី២៥ឆ្នាំមុន អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ក៏ត្រួតពិនិត្យមើល គណបក្សនយោបាយចំនួន២០ដែរ ភាគច្រើននៃគណបក្សទាំងនោះ ក៏ទើបបង្កើតថ្មីដែរ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតលើកទី១ បន្ទាប់ពីកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា ត្រូវបានចុះហត្ថលេខានៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១។ ទោះជាយ៉ាងណាក៏ដោយ គ្មានការបោះឆ្នោតណាមួយអាចត្រូវចាត់ទុកថាជាការបោះឆ្នោតពិតប្រាកដនោះទេ ប្រសិនបើគណបក្សប្រឆាំងដ៏ធំ ត្រូវបានហាមឃាត់មិនឲ្យចូលរួម ហើយសមាជិកជាន់ខ្ពស់១១៨រូប របស់ខ្លួនត្រូវបានហាមឃាត់មិនឲ្យឈរឈ្មោះនោះ។

## IX. ការគ្រប់គ្រងវិស័យយុត្តិធម៌

៧៩. អ្នករាយការណ៍ពិសេស សូមសម្តែងនូវសេចក្តីសោមនស្សដែលបានជ្រាបថា ក្រសួងយុត្តិធម៌ បានទទួលនូវការកើនឡើងនៅក្នុងថវិការបស់ខ្លួន ហើយកំពុងតែធ្វើឲ្យមានការរីកចំរើនលើគំនិតផ្តួចផ្តើមមួយចំនួន ដែលធ្លាប់បានពិភាក្សាគ្នាជាយូរមកហើយ។ សំណុំរឿងព្រហ្មទណ្ឌជាង២៣០០០ សំណុំរឿង ត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្ន័យសំណុំរឿងព្រហ្មទណ្ឌ ហើយក្រសួងយុត្តិធម៌បានកត់សំគាល់នៅក្នុងកិច្ចពិភាក្សាស្តីពីលទ្ធភាពនៃការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅថ្នាក់កណ្តាលមួយ ហើយបន្ទាប់មកនឹងមានការចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណី និងឆ្លោះទៅបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងរួមបន្ថែមទៀតផង។ អ្នករាយការណ៍ពិសេសក៏សូមស្វាគមន៍ដល់ការបង្កើនថែមទៀត ដល់មូលនិធិសម្រាប់ការពារជនក្រីក្រ និងការបង្កើតគោលនយោបាយជាតិសម្រាប់ការពារជនក្រីក្រ ហើយសូមទទូចឲ្យរដ្ឋាភិបាលបង្កើតឲ្យបានពេញលេញ និងផ្តល់ធនធានគ្រប់គ្រាន់ដល់គោលនយោបាយនេះ។

៨០. អ្នករាយការណ៍ពិសេស នៅតែមានក្តីកង្វល់ពីអសង្គតិភាពក្នុងការប្រើប្រាស់ភ័ស្តុតាងក្នុងរឿងព្រហ្មទណ្ឌ។ មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាបទប្បញ្ញត្តិគោលនៅក្នុងករណីនេះ។ គ្មានគោលការណ៍ណែនាំបន្ថែមអំពីការវាយតម្លៃភ័ស្តុតាងនោះទេ។ នៅពេលអ្នករាយការណ៍-ពិសេសកត់សម្គាល់អំពីការចង្អុលបង្ហាញរបស់រដ្ឋាភិបាលថាការចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាគោលការណ៍ណែនាំគ្រប់គ្រាន់សម្រាប់ចៅក្រម ការអនុវត្តន៍ជាក់ស្តែងពាក់ព័ន្ធនឹងភ័ស្តុតាង តែងតែមានការប្រែប្រួល។ តួយ៉ាង ដូចជាមានឧទាហរណ៍ជាច្រើន ដែលចៅក្រមសាលាឧទ្ធរណ៍ បានបដិសេធនូវការផ្តន្ទាទោសរបស់ចៅក្រមថ្នាក់ក្រោម ដោយសារមូលហេតុខ្វះភ័ស្តុតាង ប៉ុន្តែការអនុវត្ត មិនដូចគ្នាទាំងអស់នៅក្នុងគ្រប់រឿងក្តីនោះទេ។ ដូចដែលបានពោលអះអាងខាងលើសេចក្តីសម្រេចរបស់តុលាការកំពូលរំលាយគណបក្សសង្គ្រោះជាតិ លើកឡើងជាកង្វល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែការប្រើប្រាស់ភ័ស្តុតាងនេះឯង។ ក្រសួងយុត្តិធម៌ គួរពិចារណាបង្កើតគោលការណ៍ណែនាំច្បាស់លាស់អំពីស្តង់ដារសមស្រប និងការវាយតម្លៃលើភ័ស្តុតាង។ យើងអាចរៀនសូត្រពីការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៨១. នៅក្នុងខែមីនា ឆ្នាំ២០១៨ អ្នករាយការណ៍ពិសេសបានយកឱកាសជួបជាមួយមន្ត្រីជាន់ខ្ពស់តុលាការ។ លោកស្រីបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះការងារនៅសាលាឧទ្ធរណ៍លើការពង្រឹងការលើកសំអាងហេតុផ្លូវច្បាប់ និងការពិភាក្សាស្តីពីការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់តុលាការ។ ពង្រឹងតម្លាភាពថែមទៀតក្នុងការធ្វើសេចក្តីសម្រេចរបស់តុលាការ គួរតែនាំឲ្យមានភាពច្បាស់លាស់ថែមទៀតខាងផ្លូវច្បាប់ ការធ្វើសេចក្តីសម្រេចកាន់តែស្របគ្នាថែមទៀតលើភ័ស្តុតាង និងការអនុវត្តច្បាប់ ដែលការណ៍អាចពង្រឹងទំនុកចិត្តដល់សាធារណជនទៅលើប្រព័ន្ធតុលាការ។ ការបោះពុម្ពផ្សាយសេចក្តីសម្រេច និងសំអាងហេតុផ្លូវច្បាប់នឹងផ្តល់អត្ថប្រយោជន៍ផងដែរដល់សាកលវិទ្យាល័យនានា និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នៅក្នុងការងារដ៏សំខាន់របស់ពួកគេលើការអប់រំអ្នកវិជ្ជាជីវៈច្បាប់នាពេលអនាគត។ គម្រោងផ្តល់វគ្គបណ្តុះបណ្តាលពេញលេញ និងការដាក់ពង្រាយចៅក្រមសាលាឧទ្ធរណ៍នៅតាមសាលាឧទ្ធរណ៍ថ្នាក់តំបន់ ក៏ត្រូវបានលើកទឹកចិត្តផងដែរ។ ការណ៍នេះនឹងធ្វើឲ្យយុត្តិធម៌

កាន់តែមានភាពងាយស្រួល និងអាចលុបបំបាត់តម្រូវការឲ្យជនជាប់ឃុំជាច្រើន ត្រូវធ្វើដំណើរមករាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងសវនាការរបស់សាលាឧទ្ធរណ៍។

៨២. អ្នករាយការណ៍ពិសេស ស្នើដល់ក្រសួងយុត្តិធម៌ឲ្យជំរុញមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌នៅមូលដ្ឋាន និងកម្មវិធីអប់រំពាក់ព័ន្ធ ដើម្បីគាំទ្រឲ្យមានការប្រើប្រាស់កាន់តែច្រើនចំពោះសេចក្តីសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ជាជាងការឃុំខ្លួនបណ្តោះអាសន្ន) និងដើម្បីបំពេញបន្ថែមលើផែនការស្តីពីជម្រើសនៃការដាក់ទោសជំនួសឲ្យការឃុំខ្លួនក្នុងពន្ធនាគារ។

៨៣. សំណុំរឿងចំនួនពីរកំពុងដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សេចក្តីសន្និដ្ឋានបិទការសួរដេញដោលក្នុងសំណុំរឿងលេខ ០០២/០២ សំណុំរឿងទីពីរ ប្រឆាំងនឹងលោក នួន ជា និង លោក ខៀវ សំផន បានបញ្ចប់នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ ការសម្រេចសេចក្តីរំពឹងថានឹងធ្វើនៅក្នុងឆ្នាំ២០១៨។ សំណុំរឿង ០០៣ ប្រឆាំងនឹងលោក មាស មុត បានឈានដល់ដំណាក់កាលធ្វើសេចក្តីសន្និដ្ឋានស្ថាពរដោយសហព្រះរាជអាជ្ញានៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។ សំណុំរឿងលេខ ០០៤ ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម, លោក អោ អាន, និង លោក យឹម ទិត ត្រូវបានបំបែកជាសំណុំរឿងបីផ្សេងគ្នា។ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ការស៊ើបអង្កេតក្នុងសំណុំរឿងលេខ ០០៤ ត្រូវបានបិទជាលើកទីពីរ។

## X. ការធ្វើរបាយការណ៍ទៅកាន់ស្ថាប័នសន្ធិសញ្ញា និង ការត្រួតពិនិត្យជាសកលតាមកាលកំណត់

៨៤. កម្ពុជានៅមានរបាយការណ៍ទៀងទាត់មួយចំនួនបានហួសកាលកំណត់ត្រូវដាក់ជូនស្ថាប័នសន្ធិសញ្ញា, របាយការណ៍ទីបីនៃអនុសញ្ញាប្រឆាំងទារុណកម្ម ការប្រព្រឹត្ត ឬទណ្ឌកម្មដទៃទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប, របាយការណ៍ដំបូងនៃអនុសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ, របាយការណ៍ដំបូងនៃអនុសញ្ញាស្តីពីសិទ្ធិរបស់ជនដែលមានពិការភាព និងរបាយការណ៍រួមគ្នាទីប្រាំ និងទីប្រាំមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ របាយការណ៍រួមគ្នា ចាប់ពីរបាយការណ៍ទីបួនដល់របាយការណ៍ទីប្រាំមួយ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារបានឈានដល់ពេលកំណត់ក្នុង ខែឧសភា ឆ្នាំ២០១៨ ហើយអ្នករាយការណ៍ពិសេសយល់ថារបាយការណ៍នេះនឹងត្រូវដាក់បញ្ជូននៅពេលដ៏ឆាប់ខាងមុខនេះ។ របាយការណ៍រួមគ្នា ចាប់ពីរបាយការណ៍ទីដប់បួន ដល់ ទីដប់ប្រាំមួយ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ត្រូវបានបញ្ជូនទៅកាលពីខែមីនា ហើយរបាយការណ៍ទីប្រាំមួយ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវបានបញ្ជូនក្នុងខែមេសា។ នាពេលបច្ចុប្បន្ន របាយការណ៍ហួសកាលកំណត់ដទៃទៀត ត្រូវបាននិងកំពុងដំណើរការព្រាង។

៨៥. របាយការណ៍ទីបី នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នឹងឈានដល់កាលកំណត់នៅក្នុងអំឡុងពេលធ្វើរបាយការណ៍បន្ទាប់។

៨៦. របាយការណ៍ថ្នាក់ជាតិសម្រាប់វដ្តទីបី នៃការពិនិត្យរបាយការណ៍ឡើងវិញជាសាកលតាមកាលកំណត់ របស់រដ្ឋភាគី គួរតែត្រូវបានដាក់ជូននៅខែ វិច្ឆិកា ឆ្នាំ២០១៨ ខណៈដែលកម្ពុជាគ្រោងនឹងធ្វើការពិនិត្យរបាយការណ៍ឡើងវិញដោយក្រុមការងារក្រុមប្រឹក្សាសិទ្ធិមនុស្សនៅសម័យប្រជុំលើកទីសាមសិបពីរ របស់ខ្លួន (ខែ មករា / កុម្ភៈ ២០១៩)។ អ្នករាយការណ៍ពិសេសលើកទឹកចិត្តឲ្យរដ្ឋាភិបាលចូលរួមក្នុងកិច្ចប្រឹងប្រែងរួមគ្នាដើម្បីពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ផ្សេងៗក្នុងអំឡុងពេលធ្វើសេចក្តីព្រាងរបាយការណ៍ រួមទាំងអង្គការសង្គមស៊ីវិល ក៏ដូចជាការអនុម័តផែនការអនុវត្តមួយបន្ទាប់ពីការពិនិត្យឡើងវិញ ហើយបន្ថែមពីលើនេះទៀតគឺរបាយការណ៍សម្រាប់ដាក់ជូនទៅស្ថាប័នសន្ធិសញ្ញា។ ក្រុមការងារអន្តរក្រសួងបង្កើតថ្មីដែលដឹកនាំការងារធ្វើរបាយការណ៍ស្តីពីសិទ្ធិមនុស្ស

នៅកម្ពុជាសម្រាប់បញ្ជូនទៅអង្គការសហប្រជាជាតិ គួរតែផ្តល់នូវឱកាសមួយដើម្បីពង្រឹងការអនុវត្តល្អៗ សម្រាប់កិច្ចសហការគ្នា និងដំណើរការរៀបចំសេចក្តីព្រាង របាយការណ៍និងការតាមដានការអនុវត្ត តាមរយៈការព្រមព្រៀងគ្នាបង្កើតឲ្យមានផែនការអនុវត្ត។

## XI. លិខិតឧបាស្រ័យទៅរដ្ឋាភិបាល

៨៧. ក្នុងរយៈពេលចាប់ពីខែមិថុនា ឆ្នាំ២០១៧ ដល់ ខែមិថុនា ឆ្នាំ២០១៨ យើងសម្តែងស្វាគមន៍ចំពោះចំនួនចម្លើយតបទៅនឹងលិខិតឧបាស្រ័យដែលបានផ្ញើទៅរដ្ឋាភិបាល។ នៅក្នុងអំឡុងពេលនោះ មានលិខិតឧបាស្រ័យចំនួន ១១៖ លិខិតអំពាវនាវជាបន្ទាន់ចំនួន ៥, លិខិតអះអាងចោទប្រកាន់ចំនួន២ និងលិខិតចំនួន ៤ ផ្សេងទៀតត្រូវបានប្តឹងឧបាស្រ័យទៅរដ្ឋាភិបាល។លិខិតទាំងនោះ ត្រូវបានបញ្ជូនដោយអ្នកជំនាញបំពេញការងារតាមអាណត្តិប្រចាំប្រទេស និង/ឬដោយយន្តការផ្សេងទៀតនៃនីតិវិធីពិសេស។ អ្នករាយការណ៍ពិសេសបានចេញសេចក្តីប្រកាសព័ត៌មានចំនួនប្រាំបី។ ប្រធានបទដែលធំបំផុតគឺការចូលរួមនយោបាយនិងសេរីភាពក្នុងការបញ្ចេញមតិ។

៨៨. លើសពីនេះទៅទៀត នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៨ ក្រុមការងារស្តីពីការឃុំខ្លួនតាមដោយបំពានបានកំណត់ថា ការបន្តឃុំខ្លួនលោក កឹម សុខា គឺជាការឃុំខ្លួនដោយបំពាន (A/HRC/WGAD/២០១៨/៩) ។ រដ្ឋាភិបាលបានទទួលលិខិតឧបាស្រ័យពីក្រុមការងារនេះ ហើយមិនទាន់ឆ្លើយតបយ៉ាងណាចំពោះការលើកឡើងនោះនៅឡើយទេ។

## XII. សេចក្តីសន្និដ្ឋាន

៨៩. ស្ថានភាពទូទៅខាងសិទ្ធិមនុស្សនៅកម្ពុជា បានទទួលរងផលប៉ះពាល់នៅក្នុងឆ្នាំកន្លងមកនេះ។ ម្យ៉ាងទៀត ការចម្រើនបន្តមានក្នុងវិស័យសេដ្ឋកិច្ចដែលកម្ពុជាបាននិងកំពុងមាន បានត្រួសត្រាយផ្លូវសម្រាប់វឌ្ឍនភាពខាងវិស័យសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមកិច្ច ជាពិសេស ក្នុងវិស័យគាំពារសង្គម ប្រាក់ឈ្នួលអប្បបរមា ការសម្រាកលម្ហែមាតុភាព។ រដ្ឋាភិបាលបានដាក់បញ្ជូនផងដែរនូវរបាយការណ៍របស់ខ្លួនលើកទីប្រាំមួយទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដែលនឹងជួយជំរុញឲ្យមានកិច្ចសន្ទនាលើវិស័យសមភាពយេនឌ័រ និងរបាយការណ៍រួមបញ្ចូលគ្នាចាប់ពីរបាយការណ៍លើកទីដប់បួន ដល់ របាយការណ៍លើកទីដប់ប្រាំមួយរបស់ខ្លួន ទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍។ ទន្ទឹមនឹងវិស័យទាំងនេះ មានការរីកចម្រើនគួរឲ្យស្វាគមន៍ក៏មានការដើរថយក្រោយនូវវិស័យសិទ្ធិនយោបាយ និងការទទួលបានសេរីភាពជាមូលដ្ឋាន។ ការរំលាយគណបក្សសង្គ្រោះជាតិ និងការចាប់ប្រធានគណបក្សនេះ គឺលោក កឹម សុខា ដាក់ពន្ធនាគារ ហើយនិងការហាមឃាត់មន្ត្រីគណបក្សសង្គ្រោះជាតិចំនួន ១១៨ នាក់ មិនឲ្យធ្វើសកម្មភាពនយោបាយរយៈពេលប្រាំឆ្នាំ និងការធ្វើការបែងចែកអាសនៈរបស់គណបក្សនេះទៅឲ្យតំណាងគណបក្សផ្សេងទៀតដែលមិនបានជាប់ឆ្នោត បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិនយោបាយ។ ការបង្កើតច្បាប់ គោលនយោបាយ និងការអនុវត្ត រួមទាំងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលបើកផ្លូវឲ្យមានច្បាប់ស្តីពីការប្រមាថចំពោះអង្គព្រះមហាក្សត្រ មានគោលដៅបំបិទសំឡេងប្រឆាំង និងរិះគន់ និងដែលរឹតត្បិតយ៉ាងខ្លាំងដល់សេរីភាពជាមូលដ្ឋាន។ ការវិត្តន៍ទាំងនេះមានសភាពធ្ងន់ធ្ងរ។ ដើម្បីឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រព្រឹត្តទៅបានប្រកបដោយចីរភាព ការមិនអាចកាត់ផ្តាច់ចេញបានពីសិទ្ធិដែលតម្រូវឲ្យមានការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គួរតែដើរទន្ទឹមគ្នាជាមួយនឹងការរីកចម្រើនផ្នែកសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម។

៩០. ដោយឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រកម្ពុជា អ្នករាយការណ៍ពិសេសគូសបញ្ជាក់ជាថ្មីថាសិទ្ធិមនុស្សមានសារៈសំខាន់ណាស់សម្រាប់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍យូរអង្វែង។ ទស្សនទាននេះផ្អែកលើធម្មនុញ្ញអង្គការសហប្រជាជាតិ និងក្នុងរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទស្សនៈទាននេះ បានឆ្លុះបញ្ចាំងផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថាកម្ពុជាជា "កោះសន្តិភាព" ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ និងការអភិវឌ្ឍន៍ជាតិឲ្យសម្បូររុងរឿងជានិច្ចនិរន្តរ៍។

៩១. ដោយឃើញសន្ទុះនៃវឌ្ឍនភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ចឆាប់រហ័សនៅកម្ពុជា ឥឡូវនេះ ដល់ពេលត្រូវផ្តោតលើការបំពេញឲ្យបានគត់មត់ដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងការបង្កើតផែនការសកម្មភាពដែលមានគោលដៅច្បាស់លាស់ ដើម្បីធានាថាប្រជាជនកម្ពុជាគ្រប់រូបអាចទទួលបានផលប្រយោជន៍ស្មើភាពគ្នាពីការអភិវឌ្ឍន៍នេះ។ អ្នករាយការណ៍ពិសេសសង្ឃឹមរង់ចាំទទួលផែនការមូលដ្ឋានូបនីយកម្មសម្រាប់គោលដៅទាំងនេះ និងដើម្បីធ្វើការងារជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា និងសង្គមស៊ីវិល ឈានទៅសម្រេចគោលដៅទាំងនេះ។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសមានគោលបំណងផ្តោតការយកចិត្តទុកដាក់សម្រាប់របាយការណ៍បន្ទាប់របស់លោកស្រី លើទិដ្ឋភាពសិទ្ធិមនុស្សក្នុងកិច្ចការមូលដ្ឋានូ-បនីយកម្មសម្រាប់គោលដៅទាំងនេះ។

## XIII. អនុសាសន៍

៩២. អ្នករាយការណ៍ពិសេស បញ្ជាក់ជាថ្មីពីបំណងរបស់លោកស្រី ក្នុងធ្វើការងារជាមួយ រដ្ឋាភិបាល ដើម្បីការពារ គោរព និងលើកកម្ពស់សិទ្ធិមនុស្ស សម្រាប់ជាប្រយោជន៍ដល់ប្រជាជនគ្រប់រូបនៅប្រទេសកម្ពុជា។ តាមរយៈការគាំទ្ររដ្ឋាភិបាលសំដៅធ្វើឲ្យមានវឌ្ឍនភាពពិតប្រាកដឈានទៅអនុវត្តអនុសាសន៍មួយចំនួន និងក្នុងការបន្តកិច្ចពិភាក្សាលើបញ្ហានោះ អនុសាសន៍មួយចំនួនខាងក្រោមនេះ ត្រូវបានគូសបញ្ជាក់សម្រាប់ការចាត់វិធានការបន្ទាន់។ រដ្ឋាភិបាលគួរៈ

ក. រៀបចំសន្និសីទថ្នាក់ជាតិមួយក្នុងឆ្នាំ ២០១៩ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងទីភ្នាក់ងារអង្គការសហប្រជាជាតិនានា ដើម្បីរៀបចំផែនការមួយដែលមានការសម្របសម្រួល សម្រាប់ការអនុវត្តអនុសាសន៍នានាដែលបានពីការពិនិត្យរបាយការណ៍ ជាសកលតាមកាលកំណត់ពីស្ថាប័នសន្ធិសញ្ញាផ្សេងៗ និងពីនីតិវិធីពិសេស។

ខ. រៀបចំបញ្ចប់និងបោះពុម្ពផ្សាយផែនការ និងគោលនយោបាយស្តីពីមូលដ្ឋានូបនីយកម្មសំដៅទទួលបានលទ្ធផលជោគជ័យដែលមានលក្ខណៈអាចវាស់វែងបាន ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

គ. ធ្វើឲ្យមានភាពសាមញ្ញ ឬងាយស្រួលសម្រាប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព

និងរៀបចំគម្រោងផែនការមួយ ដែលមានគោលដៅច្បាស់លាស់ ដើម្បីសម្រេចការងារនេះ។

ឃ. ប្រសិនជាករណីនេះមិនទាន់មាន ត្រូវធ្វើឲ្យប្រាកដថា តារាងបញ្ជាក់ពីប្រាក់ប្រដាប់ក្តី ត្រូវបិទផ្សាយជាសាធារណៈជាភាសាខ្មែរ នៅគ្រប់តុលាការទាំងអស់ ហើយប្រាក់ត្រូវបង់បន្ថែម ដែលក្រឡាបញ្ជីអាចនឹងតម្រូវឲ្យបង់តាមច្បាប់នោះ ក៏ត្រូវតែបានពិនិត្យពិច័យ និងត្រូវបិទផ្សាយជាសាធារណៈផងដែរ។

ង. ធានាថាសេចក្តីជូនដំណឹងដែលគូសបញ្ជាក់អំពីការមិនតម្រូវឲ្យបង់ប្រាក់ទៅអនុរក្ស ឬបុគ្គលិកពន្ធនាគារ ត្រូវបិទផ្សាយឲ្យគេអាចមើលឃើញបានច្បាស់លាស់ជាភាសាខ្មែរ នៅតាមច្រកចូល នៃមណ្ឌលឃុំឃាំងទាំងអស់។

ច. បង្កើតសៀវភៅណែនាំមួយ ស្តីពីការប្រមូល ការវាយតម្លៃការប្រើប្រាស់ និងការទុក ដាក់ភ័ស្តុតាង ដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌។

ឆ. បន្ត និងពន្លឿនការចងក្រងសេចក្ដីសម្រេចសំខាន់ៗនៅសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។

ជ. ផ្ដល់គោលការណ៍ណែនាំដែលចេញដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទៅដល់ចៅក្រមគ្រប់រូប ដើម្បីប្រើប្រាស់ទម្រង់នៃការឃុំខ្លួនបណ្ដោះអាសន្នជាមធ្យោបាយលើកទឹកចិត្តឲ្យមានបញ្ជាក់ហេតុផល ក្នុងសាលក្រមឬសាលដីកា សម្រាប់សេចក្ដីសម្រេចពាក់ព័ន្ធផ្សេងៗ និងស្វែងរកការគាំទ្រលើការកសាងសមត្ថភាព តាមការចាំបាច់។

ឈ. ដោះលែងជនជាប់ឃុំទាំងឡាយ ដែលត្រូវបានចោទប្រកាន់ និងដាក់ពន្ធនាគារដោយគ្មានភ័ស្ដុតាងរឹងមាំគ្រប់គ្រាន់ និងអ្នកទាំងឡាយដែលត្រូវបានចាប់ខ្លួន ដោយសារហេតុផលនយោបាយ ការងារសិទ្ធិមនុស្ស ឬការបញ្ចេញមតិយោបល់របស់ខ្លួន។

ញ. លុបការហាមឃាត់ការចូលរួមក្នុងសកម្មភាពនយោបាយចេញពីអតីតសមាជិកទាំង ១១៨ រូបរបស់គណបក្សសង្គ្រោះជាតិ និងប្រគល់កៅអីសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្សសង្គ្រោះជាតិ និងប្រគល់តួនាទីមុខតំណែងជាមេឃុំ-ចៅសង្កាត់ដល់អ្នកដែលបានឈ្នះឆ្នោតពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងខែមិថុនាឆ្នាំ២០១៧ កន្លងទៅនេះ ឲ្យទៅពួកគេវិញ។

៩៣. អនុសាសន៍ខាងក្រោមនេះ ដែលបានរំលេច សម្រាប់ធ្វើការពិចារណា ដើម្បីកំណត់ពីមធ្យោបាយដែលល្អបំផុតដើម្បីធ្វើឲ្យប្រាកដថាមានច្បាប់ និងការអនុវត្ត សមស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋាភិបាលគួរ៖

ក. លុបចោលបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដែលអាចត្រូវគេប្រើប្រាស់ដើម្បីរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិការជួបប្រជុំ និងការបង្កើតសមាគម ក្នុងគោលដៅធ្វើឲ្យកាន់តែមានលក្ខណៈសមស្របថែមទៀតទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដោយលុបចេញពីបទល្មើសព្រហ្ម-ទណ្ឌ ដូចជា ការបរិហារកេរ្តិ៍ ជាដើម។

ខ. ធ្វើឲ្យប្រាកដថា សំណៅចុងក្រោយនៃក្រមស្ដីពីបរិស្ថាន និងធនធានធម្មជាតិ ផ្ដោតការយកចិត្តទុកដាក់លើមតិត្រឡប់របស់អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។

គ. បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីកត់ត្រានិងរាយការណ៍ជាប្រព័ន្ធករណីតាមអង្គច្បាប់ដោយមានសេចក្ដីសង្ខេបពីហេតុផល និងផ្ដល់ការបណ្ដុះបណ្ដាលពេញលេញដល់ស្ថាប័នតុលាការស្ដីពីមាតិកានៃសៀវភៅស្ដីពីភ័ស្ដុតាង នៅពេលដែលសៀវភៅនោះ ធ្វើរួចរាល់។

ឃ. បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការឃុំខ្លួនជាបណ្ដោះអាសន្ន ហើយប្រើប្រាស់ជម្រើសជំនួសការឃុំខ្លួនក្នុងពន្ធនាគារ ក្នុងករណីសមស្រប គាំទ្រវិធានការនេះតាមរយៈការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងយុទ្ធនាការផ្សព្វផ្សាយពត៌មាន។

ង. បង្ហាញពីគោលការណ៍ណែនាំស្ដីពីការអនុវត្តទោសជំនួសដើម្បីពង្រឹងការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន និងបទប្បញ្ញត្តិពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌ។

ច. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងបោះពុម្ពផ្សាយរាល់សេចក្ដីសម្រេចរបស់តុលាការគ្រប់ជាន់ថ្នាក់។

ឆ. តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ដល់ថវិកាលៃបម្រុងគ្រប់គ្រាន់សម្រាប់ដំណើរការផ្ដល់ ប័ណ្ណកម្មសិទ្ធិសមូហភាព ក៏ដូចជា សម្រាប់ជំនួយផ្នែកច្បាប់។

ជ. ប្រើប្រាស់វិធានការការពារបណ្ដោះអាសន្ន សម្រាប់ជនជាតិដើមភាគតិច តាមមាត្រា ២៣ កថាខណ្ឌទី២ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ សំដៅបញ្ឈប់រាល់ទម្រង់នៃការជួញដូរដីធ្លី រហូតដល់ពេលសហគមន៍ពាក់ព័ន្ធទទួលបានសេចក្ដីសម្រេចស្ថាពរលើការទាមទារប័ណ្ណកម្មសិទ្ធិដីសហគមន៍របស់ខ្លួន។

ឈ. ធានាថាមជ្ឈមណ្ឌលទាំងឡាយដែលទទួលយកអ្នកប្រើប្រាស់គ្រឿងញៀន និងសារធាតុញៀនដទៃទៀត ព្រមទាំងមជ្ឈមណ្ឌលដែលផ្តល់ការគាំទ្រដល់ជនដែលមានពិការភាពចិត្តសង្គម និងពិការភាពផ្សេងទៀត បានទទួលធនធានគ្រប់គ្រាន់ និងអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធ។

ញ. ធ្វើការពិនិត្យឡើងវិញលើកម្មវិធីជាតិប្រឆាំងគ្រឿងញៀន ដោយត្រូវរួមបញ្ចូលនូវទស្សនទានផ្នែកសិទ្ធិមនុស្ស។

ដ. ធ្វើការងារស្របតាមកាលវិភាគរំកិល សំដៅធានាថាកាតព្វកិច្ចធ្វើរបាយការណ៍ស្របតាមសន្ធិសញ្ញានានារបស់អង្គការសហប្រជាជាតិ ត្រូវបានបំពេញទាន់ពេលវេលាកំណត់។

---